# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2012, 10:46
CMS/CFO: Phok Chanthan

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* ខាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម CARTWRIGHT និង អ្នកដទៃទៀត

---

<u>ដាក់ដោយ៖</u>

ក្រុមមេធាវីការពារក្តីលោក អៀង សារី ៖

អាង ឧត្តម

Michael G. KARNAVAS

<u>អង្គជំនុំជម្រះសាលាដំបូង៖</u>

ចៅក្រម និល ណុន ប្រធាន

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង ធួ មណី

ចៅក្រមបម្រុង Claudia FENZ

សហព្រះរាជអាជ្ញា៖

ជា លាង

Andrew CAYLEY

ក្រុមមេធាវីការពារក្ដីគ្រប់ក្រុម

ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់គាត់ (“ក្រុមមេធាវីការពារក្តី”) សូមដាក់សំណើឱ្យស៊ើបអង្កេតអំពីការប្រាស្រ័យទាក់ទងតែជាមួយភាគីម្ខាងរវាងលោក Andrew Cayley សហព្រះរាជអាជ្ញាបរទេស និងលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត អនុលោមតាមវិធាន ៣៥ ៤១ និង ៩៣ នៃវិធានផ្ទៃក្នុងអ.វ.ត.ក (“វិធាន”)។ សំណើនេះ ត្រូវធ្វើឡើងជាចាំបាច់ដើម្បីបង្ហាញឱ្យដឹងគ្រប់ជ្រុងជ្រោយអំពីការប្រាស្រ័យទាក់ទងតែជាមួយភាគីម្ខាង រវាងលោក Cayley និងលោកស្រីចៅក្រម Cartwright ជាពិសេសរួមមាន៖ **ក.** បញ្ជីនូវរាល់កិច្ចប្រជុំទាំងអស់ដែលលោក Cayley និងលោកស្រីចៅក្រម Cartwright បានចូលរួមក្នុងជំនួប*សម្ងាត់* ទោះជាជំនួបនោះមានការចូលរួមពីអ្នកដទៃក៏ដោយ[1] ឱ្យតែមានកិច្ចពិភាក្សាទាក់ទងនឹងសំណុំរឿង០០២ ដោយផ្ទាល់ឬ ដោយប្រយោល និង **ខ.** អង្គហេតុ និងព័ត៌មានលម្អិតដែលពាក់ព័ន្ធទាំងអស់ទាក់ទងនឹងជំនួប*សម្ងាត់*ទាំងនោះ[2] ក្នុងនោះមានមិនកំណត់ត្រឹមតែរបៀបវារៈ និង/ឬកំណត់ហេតុនៃកិច្ចប្រជុំ (បើទោះជាការកត់ត្រាមិនផ្លូវការ និង/ឬសរសេរដោយដៃក៏ដោយ) (ទាំងនោះជា “ព័ត៌មានដែលត្រូវបានស្នើឡើង”)។ ការប្រាស្រ័យទាកទងតែជាមួយ*ភាគីតែម្ខាង* រវាងចៅក្រម និងសហព្រះរាជអាជ្ញាដែលចូលរួមក្នុងការជំនុំជម្រះក្តីលើសំណុំរឿងតែមួយ ជាការរំលោភលើវិធាននៃក្រមសីលធម៌វិជ្ជាជីវៈ និងអាចបង្កើតឱ្យមានភាពលំអៀង។ ដោយហេតុថាការប្រព្រឹត្តបែបនេះ ក៏អាចជ្រៀកជ្រែតចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការផងដែរនោះ ក្រុមមេធាវីការពារក្តី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តសិទ្ធអំណាចរបស់ខ្លួនដើម្បីស៊ើបអង្កេតដោយ **ក.** *កោះឱ្យ*លោក Cayley អ្នកស្រី Ms. Patricia O’Brien និងលោក Knut Rosadhaug និងអ្នកដទៃទៀត (ដែលជាប់ពាក់ព័ន្ធ ឬមិនជាប់ពាក់ព័ន្ធជាមួយអវតក រួមទាំង តែមិនកម្រិតត្រឹមអ្នកការទូត និងតំណាងរបស់រដ្ឋាភិបាលបរទេស) ដែលបានចូល

---

[1] ឧទាហរណ៍ ជំនួបជាមួយបុគ្គលិកអង្គការសហប្រជាជាតិ និងសហគមន៍អ្នកការទូតតំណាងឱ្យប្រទេសផ្តល់ជំនួយ។ ពាក់ព័ន្ធនឹងការជ្រៀតជ្រែករបស់សមាជិកសហគមន៍អ្នកការទូតតំណាងប្រទេសផ្តល់ជំនួយ ចូលក្នុងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ *សូមមើល* អត្ថបទ Mike Eckel *តុលាការ Kangaroo ក្នុងប្រទេសកម្ពុជា* ដោយទស្សនាវដ្តី FOREIGN POLICY ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១៖ “មន្ត្រីរបស់ប្រទេសផ្តល់ជំនួយសំខាន់ៗដល់តុលាការ ក្នុងនោះមានសហរដ្ឋអាមេរិក អូស្ត្រាលី និង ប្រទេសដទៃទៀត [ត្រូវបានជំរុញឱ្យ]” ធ្វើអន្តរាគមន៍ដោយផ្ទាល់ជាមួយលោក Blunk [សហចៅក្រមស៊ើបអង្កេត] និង លោក Andrew Cayley [សហព្រះរាជអាជ្ញាអន្តរជាតិ] ជាច្រើនលើកតាមទូរស័ព្ទ ឬដោយផ្ទាល់។” *សូមមើលផងដែរ* លិខិតរបស់លោក អាង ឧត្តម និងលោក Michael G Karnavas សរសេរទៅកាន់និពន្ធនាយកទស្សនាវដ្តី FOREIGN POLICY ៖ *អ្នកផ្តល់ជំនួយ និងអ្នកការទូត សម្តែងការមិនពេញចិត្តចំពោះការជ្រៀតជ្រែកខាងនយោបាយនៅ អ.វ.ត.ក ដោយធ្វើការជ្រៀតជ្រែកខាងនយោបាយដោយខ្លួនឯងផ្ទាល់* ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១។

[2] ឧទាហរណ៍ តើវិបត្តិនាពេលបច្ចុប្បន្ន និងការផ្សព្វផ្សាយព័ត៌មានអវិជ្ជមានពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង ០០៤ មានផលប៉ះពាល់លើសំណុំរឿង០០២ យ៉ាងដូចម្តេច?

រួមក្នុងជំនួបតែជាមួយភាគីម្ខាង ជាមួយលោក Cayley និងលោកស្រីចៅក្រម Cartwright ("បុគ្គលដែលស្នើសុំឲ្យផ្តល់ព័ត៌មាន") ផ្តល់នូវព័ត៌មានដែលបានស្នើ និង **ខ.** *លើកទឹកចិត្ត*ឲ្យចៅក្រម Cartwright ចេញសេចក្តីថ្លែងការណ៍ផ្តល់ព័ត៌មានដែលបានស្នើ[3] ទោះបីជាសំណើនេះមិនមែនជាការដាក់បណ្តឹងជំទាស់ចិត្តក៏ដោយចុះ[4]។ ក្រុមមេធាវីការពារក្តីស្នើឲ្យមានសវនាការដេញដោលជាសាធារណៈដោយផ្ទាល់មាត់ ឬជាជម្រើសស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅសារណាដែលដាក់តបនឹងសំណើនេះ។ វិធីល្អបំផុតដែលត្រូវអនុវត្តចៅក្រម Cartwright គប្បី **ក.**ដកខ្លួនចេញពីការធ្វើសម្រេចលើសំណើនេះ និង **ខ.** មិនចូលរួមដោះស្រាយក្នុងបញ្ហាដែលមិនទាន់ធ្វើសេចក្តីសម្រេចហើយ ឬបំពេញការងារណាទាក់ទងនឹងការរៀបចំសម្រាប់សំណុំរឿង០០២ រហូតដល់សំណើនេះត្រូវបានដោះស្រាយហើយ ដូច្នេះបញ្ហានានាទាំងនេះនឹងមិនទទួលរងការប៉ះពាល់ បើសិនគាត់ត្រូវបានជិតចិត្តនាពេលខាងមុខ ។ សំណើនេះត្រូវបានធ្វើឡើងដោយសុចិត មិនមានបំណងពន្យារពេល ឬរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីឡើយ។ ដោយហេតុថាមានចៅក្រមបម្រុង និងតាមអ្វីដែលក្រុមមេធាវីការពារក្តីដឹងច្បាស់នោះ សហព្រះរាជអាជ្ញារងអន្តរជាតិមិនបានជាប់ពាក់ព័ន្ធនឹងជំនួបសម្ងាត់ណាមួយនោះទេ ។ ការដកខ្លួន ការជិតចិត្ត ការលាលែង ឬការដាក់វិន័យបណ្តាលមកពីជំនួបសម្ងាត់ទាំងនោះ នឹងមិនធ្វើឲ្យពន្យារពេលដល់ការចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២ ឡើយ។

## I. សិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស៊ើបអង្កេត

[3] ដូចមានចែងដោយសទិសភាព ក្នុងវិធាន៣៤ (៧)

[4] *សូមមើល* ចម្លើយតបទៅនឹងសំណើរបស់លោកអៀង សារី ស្នើឲ្យចាត់វិធានការណ៍សមស្របទៅនឹងសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជំទាស់ទៅនឹងឯករាជ្យភាពរបស់លោកស្រី Katinka Lahuis និងលោក Rowan Downing ចៅក្រមអង្គបុរេជំនុំជម្រះ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រទី៣ កថាខណ្ឌ ២ ដោយហេតុថាលោកចៅក្រម Downing និងលោកស្រីចៅក្រម Lahuis បានដាក់សារណាជាលាយលក្ខណ៍អក្សរឆ្លើយតបទៅនឹងសំណើសុំឲ្យចាត់ "វិធានការណ៍សមស្រប" ដោយមិនដាក់សារណាឆ្លើយតបទៅនឹងបណ្តឹងជិតចិត្តនោះទេ។ *សូមមើលផងដែរ រឿងក្តី Locabail (UK) Ltd. តទល់នឹង Bayfield Properties Ltd.* [2000] 2 WLR 870 at 477-78: "នៅពេលអនុវត្តលក្ខណៈវិនិច្ឆ័យលើគ្រោះថ្នាក់ជាក់ស្តែង ឬលទ្ធភាពជាក់ស្តែង (ផ្ទុយទៅនឹងលក្ខណៈវិនិច្ឆ័យនៃការជិតចិត្តដោយស្វ័យប្រវត្តិ...) ជារឿយៗ វាមានភាពសមស្របក្នុងសាកសួរថាតើចៅក្រមដឹងពីអង្គហេតុដែលខ្លួនផ្អែកដែរឬទេ ដោយហេតុថាវាត្រូវបានមើលឃើញថាប៉ះពាល់ដល់ភាពអនាគតិរបស់ចៅក្រម...។ តុលាការដែលពិនិត្យមើលបណ្តឹងសាទុក្ខ អាចទទួលសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរពីចៅក្រមជំនួយការចៅក្រម (lay justice) សមាជិកគណៈវិនិច្ឆ័យណាមួយ ដោយបញ្ជាក់ពីអ្វីដែលគាត់បានដឹងនៅពេលវេលាដែលពាក់ព័ន្ធណាមួយ ក៏ប៉ុន្តែតុលាការមិនជាប់កាតព្វកិច្ចជាចាំបាច់ក្នុងការទទួលយកសេចក្តីថ្លែងការណ៍បែបនោះក្នុងគុណតម្លៃជាក់ស្តែងឡើយ...។ ភាគីទាំងអស់ នឹងពិនិត្យមើលអង្គហេតុនៃករណីជាក់លាក់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនអាចមានចំណោទបញ្ហាចំពោះការសួរសាក្សីរបស់ភាគីបដិបក្ខ ឬការស្នើឲ្យមានការបង្ហាញពីតុលាការឡើយ"។

**សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម CARTWRIGHT និង អ្នកដទៃទៀត**

1. វិធាន ៣៥(២) ផ្តល់សិទ្ធិអំណាចអង្គជំនុំជម្រះសាលាដំបូងអនុវត្តកិច្ចស៊ើបសួរបន្ថែមនៅពេលដែលខ្លួន "មានហេតុផលជឿថា" មានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធីប្រឆាំងនឹងបុគ្គលដែលត្រូវបានដឹង និងមានចេតនាជ្រៀកជ្រែតកិច្ចការរដ្ឋបាលរបស់តុលាការ។ បទដ្ឋាននៃហេតុផលដែលត្រូវជឿត្រូវបានសម្រេចថាជា "បទដ្ឋានស្រាលបំផុត"[5] ។
2. វិធាន ៤១ (១) ផ្តល់សិទ្ធិអំណាចដល់អង្គជំនុំជម្រះសាលាដំបូងកោះហៅបុគ្គលណាម្នាក់នៅចំពោះមុខអង្គជំនុំជម្រះ។ វិធាន៤១ អាចអនុវត្តបានទន្ទឹមគ្នានឹងវិធាន ៣៥ និងវិធាន៩៣ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់ចម្លើយសាក្សី និងរឹបអូសយកភស្តុតាងក្នុងអំឡុងពេលធ្វើការស៊ើបសួរបន្ថែម។

## II. សាវតារ

3. កាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ លោក Michiel Pestman សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា បានផ្ញើសារអេឡិចត្រូនិកទៅកាន់លោក Rosandhaug[6] ដើម្បីជម្រាបថាគាត់បានទទួលដំណឹងថាលោកស្រីចៅក្រម Cartwright, លោក Cayley និងលោក Rosandhaug ផ្ទាល់បាន "ជួបប្រជុំគ្នាយ៉ាងទៀងទាត់នៅក្នុងការិយាល័យរបស់លោក ដើម្បីពិភាក្សាអំពីបញ្ហានានាទាក់ទងនឹងតុលាការ"។ លោក Pestman ស្នើចង់ឲ្យមានការបញ្ជាក់ថាតើព័ត៌មាននេះ ពិតប្រាកដដែរ ឬទេ។ ប្រសិនបើវាពិតប្រាកដមែន តើជំនួបទាំងនោះមានគោលបំណងអ្វីបានជាមិនឲ្យតំណាងភាគីដទៃទៀតចូលរួម?[7]។ ដោយហេតុថាមិនបានទទួលការឆ្លើយតបពីលោក Cayley លោក Michael G.Karnavas សហមេធាវី

---

[5] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោកនួន ជា និងលោកអៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ២០១១ ឯកសារលេខ D314/1/12, កថាខណ្ឌ 37។ អង្គបុរេជំនុំជម្រះក៏បានថ្លែងថា: "វិធាន៣៥ ត្រូវបានដាក់បញ្ចូលក្នុងវិធានផ្ទៃក្នុងជាយន្តការក្សាបាននូវសុច្ចរិតភាពនៃកិច្ចដំណើរការរបស់តុលាការនៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះក្តី។ សុច្ចរិតភាពនៃកិច្ចដំណើរការ ត្រូវបានធានាតាមរយៈការអនុវត្តដោយត្រឹមត្រូវតាមវិធាន... អង្គជំនុំជម្រះពិនិត្យមើលសកម្មភាពដែលធ្វើឡើងដោយបុគ្គលណាមួយដែលគំរាមកំហែងកិច្ចការរដ្ឋបាលរបស់តុលាការ។ ដូចខាងលើ កថាខណ្ឌ 38។

[6] លោក Rosandhaug គឺជាអនុប្រធានការិយាល័យរដ្ឋបាលរបស់ អវតក ។

[7] សារអេឡិចត្រូនិករបស់លោក Pestman ផ្ញើជូនលោក Rosandhaug ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១១

អន្តរជាតិការពារក្តីលោក អៀង សារី បានផ្ញើសារអេឡិចត្រូនិកដើម្បីសួរបញ្ជាក់លោក Cayley[8] (ដោយចម្លងជូនលោក Pestman តាមរយៈសារអេឡិចត្រូនិករបស់គាត់)។

4. កាលពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Rosandhaug បានឆ្លើយតបទៅនឹងលោក Pestman ដោយទទួលស្គាល់ថាជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, លោក Cayley និងរូបគាត់ បានធ្វើឡើងជាហូរហែរចាប់តាំងពីខែ មេសា ឆ្នាំ ២០១០ កន្លងមក[9]។

5. កាលពីថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោកអាង ឧត្តម និងលោក Karnavas សហមេធាវីការពារក្តីលោកអៀង សារី បានឆ្លើយតបទៅនឹងលិខិតរបស់លោក Rosandhaug។ ពួកគាត់បានធ្វើការកត់សម្គាល់ថា៖

> ការលេចឡើងនូវភាពមិនត្រឹមត្រូវជាច្រើន ធ្វើឲ្យមានការព្រួយបារម្ភជាទូទៅចំពោះកិច្ចដំណើរការនីតិវិធី នៅពេលដែលសហព្រះរាជអាជ្ញាមួយរូប និងចៅក្រមមួយរូបក្នុងសំណុំរឿង០០២ ជួបប្រជុំគ្នាដើម្បីពិភាក្សាការងារ ទោះជាកិច្ចការរដ្ឋបាលដែលទាក់ទងនឹង អ.វ.ត.ក ជាទូទៅក៏ដោយ...។ ដោយហេតុថា តុលាការនេះមានលក្ខណៈជាតុលាការជាតិពិសេស ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិនោះ ការប្រៀបធៀបនូវអ្វីដែលអាចកើតឡើងនៅតុលាការ

---

[8] *សូមមើល ឧទាហរណ៍* សារអេឡិចត្រូនិករបស់លោក Karnavas ផ្ញើជូនលោក Cayley ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១១៖ "សួស្តី Andrew! ជាដំបូង សូមសម្តែងការអបអរសាទរចំពោះលោកដែលត្រូវបានចំរាញ់ជាជ្រើសរើស [សម្រាប់តំណែងរដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិ]។ ខ្ញុំជឿជាក់លោកនឹងទទួលបានតួនាទីនេះ។ ទីពីរ ដូចលោកបានដឹងហើយអំពីអ្វីដែលកំពុងកើតឡើងនៅអ.វ.ត.ក នាពេលបច្ចុប្បន្ននេះ។ វាជាការល្អដែលលោកឆ្លើយតបទៅនឹងសារលិខិតទៅកាន់ Knut ឲ្យបានឆាប់តាមតែអាចធ្វើបាន! ពីខ្ញុំ Michael"

[9] សារអេឡិចត្រូនិករបស់លោក Rosandhaug ផ្ញើជូនលោក Pestman ថ្ងៃទី១ ខែ វិច្ឆិកា ឆ្នាំ ២០១១៖ លោក Rosandhaug បានពន្យល់ថាការណែនាំឲ្យជួបប្រជុំទៀងទាត់រវាងលោកស្រីចៅក្រម Cartwright, លោក Cayley និងលោក. Rosandhaug ត្រូវបានស្នើឡើងដោយលោកស្រី Patricia O'Brien អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិក្នុងអំឡុងដំណើរទស្សនៈកិច្ចរបស់លោកស្រីនៅអ.វ.ត.ក ក្នុងខែ មេសា ឆ្នាំ ២០១០។ យោងតាមលោក Rosandhaug "កិច្ចប្រជុំមានគោលដៅផ្តោតលើការប្រាស្រ័យទាក់ទងគ្នារវាងសមភាគីអង្គការសហប្រជាជាតិនៅ អ.វ.ត.ក និងការិយាល័យកណ្តាលរបស់អង្គការសហប្រជាជាតិ" ហើយ "បានជូនដំណឹងដល់សមាសភាគីជាតិជាទៀងទាត់" ។ គាត់បានបន្ថែមថាកិច្ចប្រជុំត្រូវបានធ្វើឡើងក្រៅផ្លូវការ ដោយ "យកលំនាំតាមគណៈកម្មាធិការសម្របសម្រួលដែលមានជាបទដ្ឋាននៅក្នុងសាលាក្តីរបស់អង្គការសហប្រជាជាតិ និងសាលាក្តីដែលផ្តល់ជំនួយដោយអង្គការសហប្រជាជាតិ។" កិច្ចប្រជុំទាំងនោះ ពិភាក្សាអំពីបញ្ហាទាក់ទងរដ្ឋបាល និងការចាត់ចែង និងមិនបានពិភាក្សាអំពីអង្គហេតុនៃសំណុំរឿងនានានៅចំពោះមុខអ.វ.ត.កឡើយ។ ដូចខាងលើ។

**សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយ លោកស្រីចៅក្រម CARTWRIGHT និង អ្នកដទៃទៀត**

ព្រហ្មទណ្ឌអន្តរជាតិ ("ICTY")] និងអ្វីដែលកំពុងត្រូវបានអនុវត្តនៅទីនេះ មិនមានភាពសមស្របឡើយ។ បើសិនជាសមភាគីអង្គការសហប្រជាជាតិ ចង់ឲ្យមានការសម្របសម្រួលកាន់តែប្រសើរឡើងជាមួយការិយាល័យកណ្តាលរបស់អង្គការសហប្រជាជាតិក៏ដោយ ចុះហេតុដូចម្តេចបានជាមិនឲ្យតំណាងក្រុមមេធាវីការពារក្តី និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីចូលរួមផង? ជាពិសេសនៅពេលដែលសហព្រះរាជអាជ្ញាបរទេស (ដែលកំពុងចូលរួមដោយផ្ទាល់ក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២) និងចៅក្រមមួយរូបនៃអង្គជំនុំជម្រះសាលាដំបូង (ដែលកំពុងចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ដែរ - វាផ្ទុយទៅនឹងរដ្ឋអាជ្ញា និងប្រធានអង្គជំនុំជម្រះនៅ ICTY) ជួបប្រជុំ និងពិភាក្សាបញ្ហានានាដែលប៉ះពាល់កិច្ចការរដ្ឋបាលរបស់តុលាការនៅ អ.វ.ត.ក...។ កិច្ចប្រជុំបែបនេះអាចប៉ះពាល់យ៉ាងខ្លាំងទៅលើរឿងក្តីដែលកំពុងជំនុំជម្រះ ដែលសហព្រះរាជអាជ្ញា និងចៅក្រមអង្គជំនុំជម្រះសាលាដំបូងកំពុងចូលរួម...។ យើងយល់ឃើញថាការប្រាស្រ័យទាក់ទងគ្នាណាមួយរវាងសមាជិក ក.ស.ព និងសមាជិកអង្គជំនុំជម្រះសាលាដំបូងធ្វើឲ្យយើងមានកង្វល់ ដោយហេតុថាវាតែងតែបង្កើតឲ្យមានការសង្ស័យអំពីការប្រាស្រ័យទាក់ទងគ្នា*ជាមួយភាគីតែម្ខាង* ដែលកំពុងកើតមាន [និង] យោងតាមសេចក្តីសង្កេតប្រកបដោយគតិបណ្ឌិតរបស់ Lord Hewart C.J. ក្នុងរឿងក្តី *R v. Sussex Justices, Ex parte McCarthy*៖ "មិនត្រូវផ្តល់ឲ្យត្រឹមតែយុត្តិធម៌តែប៉ុណ្ណោះទេ ប៉ុន្តែយុត្តធម៌ ត្រូវផ្តល់ឲ្យបានជាក់ស្តែង និងដោយគ្មានមន្ទិលសង្ស័យ...។ យើងយល់ឃើញថាមិនមានហេតុផលណាដែលពួកគាត់គប្បីមិនផ្តល់កំណត់ហេតុនៃកិច្ចប្រជុំពេលកន្លងមកឲ្យអង្គភាពគាំពារការការពារក្តី ក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ"[10]។

6. កាលពីថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០១១ លោក Pestman បានផ្ញើសារអេឡិចត្រូនិកទៅកាន់លោកស្រីចៅក្រម Cartwright ដោយជម្រាបគាត់ថាក្រុមមេធាវីការពារក្តីលោក នួន ជា "រង់ចាំដោយទន្ទឹងដើម្បីទទួលកំណត់ហេតុនៃជំនួបប្រជុំទាំងនេះ ដើម្បីឲ្យយើងខ្ញុំកំណត់បានថាតើមានការពិភាក្សាអំពីបញ្ហាណាមួយដែលតាមទស្សនៈរបស់យើង អាចប៉ះពាល់ [sic] សិទ្ធិជាមូលដ្ឋានរបស់កូនក្តីរបស់យើងខ្ញុំ"។ លោក Pestman កត់សម្គាល់ថាក្រុមមេធាវីការពារក្តីលោក នួន ជា បាន "<u>ឃើញព័ត៌មានបង្ហាញឲ្យដឹងថាមានជំនួបផ្សេងទៀតរវាង [លោកស្រីចៅក្រម Cartwright] និងសហព្រះរាជអាជ្ញា[អន្តរជាតិ] បានធ្វើឡើងដោយគ្មានវត្តមាន [លោក Rosandhaug] អ្នកដឹកនាំកិច្ចការរដ្ឋបាលរបស់អង្គការសហ</u>

[10] លិខិតរបស់ក្រុមមេធាវីការពារក្តីផ្ញើជូនលោក Rosandhaug ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១

ប្រជាជាតិ"។ លោក Pestman បានស្នើសុំឲ្យមានការបញ្ជាក់ថាតើព័ត៌មាននេះ ពិតប្រាកដដែរ ឬទេ។ ប្រសិនបើពិតប្រាកដមែន "តើបញ្ហាជាក់លាក់អ្វីខ្លះ ដែលត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ?"[11]។

7. កាលពីថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Cayley បានផ្ញើសារអេឡិចត្រូនិកជូនលោក Pestman ស្នើឲ្យគាត់ផ្តល់នូវ "មូលដ្ឋានសម្រាប់ការចោទយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងរូបខ្ញុំ"។ លោក Cayley បានអះអាងថាគាត់ "ភ្ញាក់ផ្អើល"ចំពោះលិខិតរបស់លោកអាង ឧត្តម និងលោក Karnavas ចុះថ្ងៃទី ២ ខែ វិច្ឆិកា ដោយបញ្ជាក់ថា "ភាពមិនស្មោះត្រង់បានកើតមាន ហើយខ្ញុំនឹងមិនអត់ឱនឲ្យវាឡើយ"។ លោក Cayley បានបន្ថែមថាលោកនឹងមិនទទួលយក "ការចោទដោយស្មានៗនោះទេ" ធ្វើឡើងក្នុងគោលបំណងដែលគាត់បានពិពណ៌នាថាជា "យុទ្ធវិធីរបស់ក្រុមមេធាវីការពារក្តី"។ លោក Cayley បានបញ្ចប់សារអេឡិចត្រូនិករបស់គាត់ដោយស្នើឲ្យលោក Pestman "ផ្តល់ឲ្យខ្ញុំនូវអាសយដ្ឋានរបស់គណៈមេធាវីប្រទេសហូឡង់។ ខ្ញុំចង់មើលវិធាននានាស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវីរបស់លោក"[12]។ លោក Pestman បានឆ្លើយតបទៅនឹងលោក Cayley នៅថ្ងៃតែមួយ ដោយបានបំពេញតាមសំណើរបស់គាត់[13]។

---

[11] សារអេឡិចត្រូនិករបស់លោក Pestman ផ្ញើជូនលោកស្រីចៅក្រម Cartwright ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (គូសបញ្ជាក់បន្ថែម)

[12] សារអេឡិចត្រូនិករបស់លោក Cayley ផ្ញើជូនលោក Pestman ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

[13] សារអេឡិចត្រូនិករបស់លោក Cayley ផ្ញើជូនលោក Pestman ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១៖

> ជូនចំពោះ Andrew
>
> ប្រសិនបើលោកចង់ប្តឹងខ្ញុំ ខ្ញុំសូមឲ្យលោកទាក់ទងគណៈមេធាវីក្នុងទីក្រុងអាំស្ទែដាំចុះ។ គណៈមេធាវីនោះមានគេហទំព័រសមរម្យមួយជាភាសាអង់គ្លេសដែលពន្យល់អំពីអ្វីដែលអ្នកចង់ធ្វើ និងប្រាប់ពីបុគ្គលដែលអាចដោះស្រាយបណ្តឹងរបស់អ្នក៖ "ព័ត៌មានស្តីពីនីតិវិធីប្តឹងមេធាវី" http://www.advocatenordeamsterdam.nl/item.html&objID=4696។ លោក G.J. Kemper ជាព្រឹទ្ធបុរសនៃគណៈមេធាវីទីក្រុងអាំស្ទែដាំ។ ខ្ញុំនឹងចម្លងសារអេឡិចត្រូនិកនេះជូនគាត់ដើម្បីឲ្យគាត់បានដឹងពីការដាក់បណ្តឹង។ ទំនងជាលោកបានដឹងហើយ ខ្ញុំក៏ជាសមាជិកមួយរូបនៃគណៈមេធាវីទីក្រុងភ្នំពេញដែរ។ គណៈមេធាវីទីក្រុងភ្នំពេញមានក្រមសីលធម៌គួរឲ្យចាប់អារម្មណ៍។ ខ្ញុំជឿជាក់ថាលោកនឹងយល់ឃើញថាវាអាចជួយលោកផងដែរ។ លោក ជីវ សុងហាក់ ប្រធានគណៈមេធាវីទីក្រុងភ្នំពេញ។ គាត់និយាយភាសាអង់គ្លេសបានល្អ ហើយអាចទំនាក់ទំនងបានតាមរយៈលេខទូរស័ព្ទ ៖ [លេខទូរស័ព្ទ]។ ខ្ញុំនឹងជួបគាត់ថ្ងៃស្អែកនេះនៅវេលាម៉ោង ១០។ ប្រសិនបើលោកមានអ្វីចង់ឲ្យខ្ញុំផ្តាំផ្ញើទៅគាត់ សូមប្រាប់ឲ្យខ្ញុំដឹងឲ្យមុនថ្ងៃស្អែក។
>
> ពីខ្ញុំ Michiel

8. នៅថ្ងៃដដែល ក្រុមមេធាវីការពារក្តីបានសរសេរលិខិតផ្ញើជូនលោក និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងថា៖

ដោយគិតពីការខិតចូលមកដល់កាន់តែជិតនូវសេចក្តីថ្លែងការណ៍បើកក្នុងសំណុំរឿង ០០២ យើងខ្ញុំសូមស្នើជាបន្ទាន់ដល់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបង្ហាញ (១) បញ្ជីលម្អិតនូវរាល់ជំនួបទាំងអស់ដែលធ្វើឡើងរវាងចៅក្រម Cartwright និងសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា និង/ឬលោក Mr Rosandhaug (២) របៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះ។[14]

9. កាលពីថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Rosandhaug បានឆ្លើយតបទៅនឹងលិខិតរបស់លោកអាង ឧត្តម និងលោក Karnavas ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១។ គាត់ បានកត់សម្គាល់ថាកិច្ចប្រជុំរវាងគាត់ លោក Cayley និងលោកស្រីចៅក្រម Cartwright "មានលក្ខណៈក្រៅផ្លូវការក្នុងស្ថានភាពពិសេស ហើយត្រូវបានធ្វើឡើងដើម្បីពិភាក្សាកិច្ចការរដ្ឋបាល និងកិច្ចការទាក់ទងនឹងប្រតិបត្តិការតែប៉ុណ្ណោះ" ហើយមិនមានធ្វើកំណត់ត្រាសម្រាប់កិច្ចប្រជុំឡើយ។ សំណើរបស់ក្រុមមេធាវីការពារក្តីសុំចូលរួមក្នុងកិច្ចប្រជុំទាំងនោះ ត្រូវបានជំទាស់[15]។

10. កាលពីថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ *ព្រឹត្តបត្រព័ត៌មាន The Cambodia Daily* បានធ្វើសេចក្តីរាយការណ៍អំពីបញ្ហានេះ។ លោក Cayley ត្រូវបានដកស្រង់សម្តីថា៖

ជាការឆ្លើយតបទៅនឹងការលើកឡើងដោយក្រុមមេធាវីការពារក្តីលោក នួន ជា និងលោកអៀង សារី៖ កិច្ចប្រជុំគ្រប់គ្រងរដ្ឋបាលបែបនេះ ត្រូវបានធ្វើឡើងនៅក្នុងតុលាការ ICC, ICTY និង ICTR។ វាជារឿងធម្មតា។ ប្រសិនបើកិច្ចប្រជុំទាំងនោះ មិនត្រូវបានធ្វើឡើងនោះ ស្ថាប័នទាំងនេះ រួមទាំង អ.វ.ត.ក នឹងមិនអាចដំណើរការបានឡើយ។

ជាការឆ្លើយតបទៅនឹងលិខិតរបស់លោក Karnavas [និងលោក អាង ឧត្តម] [ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១] ដែលលើកឡើងថាប្រធាន និងព្រះរាជអាជ្ញានៃ ICTY មិនចូលរួមក្នុងរឿងក្តី៖ នេះជាការបកស្រាយប្រាកចាកពីការពិតទាំងស្រុង...។ ប្រធាន និង អនុប្រធាននៃ

[14] លិខិតរបស់លោក Pestman, Victor Koppe, Andrew Ianuzzi និង Jasper Pauw ផ្ញើជូនចៅក្រមនិល ណុន "សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, Andrew Carley និង/ឬ Knut Rosandhaug " ឯកសារលេខ E137

[15] លិខិតរបស់លោក Rosandhaug ផ្ញើជូនលោកអាង ឧត្តម និងលោក Karnavas ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

ICTY ជាចៅក្រម ដែលចូលរួមជំនុំជម្រះក្តីរឿងក្តីដោយផ្ទាល់ (ប្រសិនបើលោក Karnavas ជំទាស់ទៅនឹងការលើកឡើងនេះ ខ្ញុំអាចផ្តល់ឧទាហរណ៍ជូនគាត់បាន ចាប់ពីឆ្នាំ ១៩៩៥ មក)។ ខុសគ្នាពីលោក Karnavas ខ្ញុំបានធ្វើការក្នុងការិយាល័យរដ្ឋអាជ្ញានៃតុលាការ ICTY អស់រយៈពេល១០ឆ្នាំ។ ខ្ញុំដឹងពីបញ្ហានេះ។[16]

11. កាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០១១ *ព្រឹត្តបត្រព័ត៌មាន The Cambodia Daily* បានចុះផ្សាយលិខិតរបស់លោក Karnavas និងលោកអាង ឧត្តម ផ្ញើជូននិពន្ធនាយក ឆ្លើយតបការលើកឡើងរបស់លោក Cayley មុនមួយថ្ងៃ៖

    ឆ្លងតាមបទពិសោធន៍រយៈពេល១០ ឆ្នាំ ជាមេធាវីការពារក្តីនៅ ICTY គាត់មិនបានដឹងពីករណីដែលរដ្ឋអាជ្ញាក្នុងរឿងក្តីមួយ ជួបប្រជុំយ៉ាងទៀងទាត់ជាមួយប្រធានរដ្ឋបាល និងចៅក្រមមួយរូបដែលជំនុំជម្រះរឿងក្តីតែមួយឡើយ។ លោក Cayley ក៏ដូចជាលោកស្រីចៅក្រម Cartwright ចូលរួមផ្ទាល់ក្នុងជំនុំរឿង០០២។ បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងរបស់អ.វ.ត.ក ដែលលោកស្រីចៅក្រម Cartwright ជំនុំជម្រះក្តី កំពុងតែជំនុំជម្រះក្តីលើតែសំណុំរឿង០០២...។ យើងមានកាតព្វកិច្ចខាងសីលធម៌ដើម្បីពិនិត្យមើលឲ្យបានដិតដល់នូវបញ្ហានៃការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* នៅពេលណាដែលមានការលើកឡើងអំពីបញ្ហានេះ។ លោក Cayley គប្បីដឹងអំពីបញ្ហានេះ[17]។

12. កាលពីកាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីលោកនួន ជា បានដាក់សំណើសុំព័ត៌មានទាក់ទងនឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright, សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល[18]។ មកដល់ពេលនេះ លោកស្រីចៅក្រម Cartwright និងលោក

---

[16] Julia Wallace, *ក្រុមមេធាវីការពារក្តីសាលាក្តីខ្មែរក្រហម ចោទប្រកាន់អំពីកិច្ចប្រជុំសម្ងាត់*, CAMBODIA DAILY, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រទី២

[17] អាង ឧត្តម & Michael G. Karnavas, *សម្តីរបស់លោក Andrew Carley "ជាសម្តីការពារខ្លួន និងប្រាកចាកការពិត"* CAMBODIA DAILY, ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១១, ទំព័រទី២

[18] សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E137/1៖ ក្នុងសំណើនេះ*រួមមាន* ក្រុមមេធាវីការពារក្តីលោក នួន ជា "ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យលោកស្រីចៅក្រម Cartwright ផ្តល់ព័ត៌មានដែលបានស្នើឡើងដោយមេធាវីការពារក្តី ដូចជា (ក) បញ្ជីនូវរាល់កិច្ចប្រជុំទាំងអស់ដែលបានធ្វើឡើងរវាងលោកស្រីចៅក្រម Cartwright ជាមួយនឹងសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា ... ដោយមិនគិតថាជំនួបនោះធ្វើឡើងដោយមិនមានការចូលរួមពីលោក

Cayley មិនបានផ្តល់ព័ត៌មានបន្ថែមដែលបានស្នើឡើយ។ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រុមមេធាវីការពារ នួន ជា បានដាក់ពាក្យប្តឹងជិតចិត្តប្រឆាំងចៅក្រម Cartwright[19] ។

## III. ច្បាប់ជាធរមាន

### ក. ការប្រាស្រ័យទាក់ទងតែជាមួយ *ភាគីម្ខាង*

13. មាត្រា ៩ នៃក្រមសីលធម៌សម្រាប់ចៅក្រមចែងក្នុងផ្នែកពាក់ព័ន្ធថា "ផ្អែកតាមគោលការណ៍ [ចំពោះមុខ[20]] ចៅក្រមមិនត្រូវប្រាស្រ័យទាក់ទងជាមួយភាគីណាមួយនៅពេលដំណើរការនីតិវិធីដោយអវត្តមាននៃភាគីម្ខាងទៀតឡើយ លើកលែងច្បាប់អនុញ្ញាត ឬភាគីម្ខាងទៀតនោះយល់ព្រម"។ កថាខណ្ឌ ៥០ នៃគោលការណ៍ណែនាំសម្រាប់ក្រមសីលធម៌ចៅក្រមរបស់ប្រទេសនូវែលសេឡង់ ចែងថា "គប្បីត្រូវយកចិត្តទុកដាក់ដើម្បីជៀសឲ្យបាននូវការប្រាស្រ័យទាក់ទងគ្នាក្នុងសង្គមរវាងអ្នកប្រកបមុខវិជ្ជាជីវៈដែលចូលរួមពាក់ព័ន្ធក្នុងរឿងក្តីក្នុងពេលបច្ចុប្បន្ននៅចំពោះមុខតុលាការ"។

14. គោលការណ៍ទី៤ របស់អង្គការសហប្រជាជាតិឆ្នាំ ១៩៨៥ ស្តីពីឯករាជ្យភាពរបស់តុលាការ ("គោលការណ៍មូលដ្ឋាន") ចែងថា "មិនត្រូវមានការជ្រៀតជ្រែក ដោយគ្មានការអនុញ្ញាត ឬដោយមិនសមរម្យចូលក្នុងដំណើរការតុលាការ"។ គោលការណ៍ទី ៦ ចែងថា "គោលការណ៍ឯករាជ្យភាពរបស់តុលាការផ្តល់សិទ្ធិ និងតម្រូវអោយតុលាការធានាថាកិច្ចដំណើរការនីតិវិធីតុលាការត្រូវប្រព្រឹត្តទៅដោយយុត្តិធម៌ ហើយនិងត្រូវគោរពសិទ្ធិនានារបស់ភាគី"។

---

Rosanhaug ក៏ដោយ [sic] និង (ខ) របៀបវារៈ និង/ឬ កំណត់ហេតុនៃកិច្ចប្រជុំ (បើទោះជាការកត់ត្រាមិនផ្លូវការ និង/ឬ សរសេរដោយដៃក៏ដោយ)។... បន្ថែមពីលើនេះមេធាវីការពារក្តីចង់ដឹងថាបញ្ហាលើអង្គសេចក្តី និង/ឬបញ្ហាទាក់ទងនឹងសំណុំរឿង០០២ ត្រូវបានយកមកពិភាក្សាក្នុងជំនួបរវាង ឬក្នុងចំណោមលោកស្រីចៅក្រម Cartwright លោក Cayley និង/ឬលោក Rosandhaug។ ពិសេសជាងនេះទៅទៀត មេធាវីការពារក្តីចង់ដឹងថាតើលោកស្រីចៅក្រម Cartwright លោក Cayley (ឬក៏សមាជិកផ្សេងទៀតរបស់ការិយាល័យសហព្រះរាជអាជ្ញា) និង/ឬ លោក Rosandhaug ដែលបានពិភាក្សាពីប្រធានបទខាងក្រោមនេះ៖ ក. ការបន្តជ្រៀតជ្រែកខាងនយោបាយពីរាជរដ្ឋាភិបាលកម្ពុជា, ខ. ការប៉ះពាល់ដោយការជ្រៀតជ្រែកលើសំណុំរឿង ០០៣ និង០០៤, គ. ការប៉ះពាល់ដោយការជ្រៀតជ្រែកលើសំណុំរឿង០០២ និង ឃ. ក្រុមមេធាវីការពារក្តីស្នើសុំឲ្យស៊ើបអង្កេតដោយឯករាជលើការជ្រៀតជ្រែកបែបនេះ។" ដូចខាងលើ កថាខណ្ឌ៦-៧។

[19] បណ្តឹងជិតចិត្តបន្ទាន់ប្រឆាំងចៅក្រម Cartwright, ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១, ឯកសារ E137/2។

[20] ពាក្យ "ចំពោះមុខ" មិនឃើញមាននៅក្នុងអត្ថបទបកប្រែជាភាសាអង់គ្លេសនៃមាត្រា ៩ នេះទេ ប៉ុន្តែពាក្យនេះត្រូវបានប្រើប្រាស់នៅ ក្នុងអត្ថបទដើមជាភាសាខ្មែរ។

15. គោលការណ៍ Bangalore ឆ្នាំ២០០២ ស្ដីពីចរិយាធម៌របស់ចៅក្រម ("គោលការណ៍ Bangalore") ត្រូវបានបង្កើតឡើង ដើម្បីពង្រឹងគោលការណ៍មូលដ្ឋាននេះ[21]។ គោលការណ៍ Bangalore ត្រូវបានត្រួតពិនិត្យឡើងវិញអោយស្របទៅតាមការអត្ថាធិប្បាយជាច្រើនមកពីប្រទេសនានា ដែលប្រកាន់តាមយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលឡូ និងខំម៉ុនឡូ[22]។ គុណតម្លៃ (value) ២ និងការអនុវត្ត (application) ២.២ ចែងថា "**ចៅក្រមត្រូវធានាថា ទង្វើរបស់ខ្លួន ទាំងនៅក្នុង និងក្រៅតុលាការរក្សា និងលើកស្ទួយនូវទំនុកចិត្តទៅលើអនាគតិរបស់ចៅក្រម និងតុលាការ ពីសាធារណជន, ពីសំណាក់វិជ្ជាជីវៈច្បាប់ និងគូភាគីវិវាទ**"។ ការអត្ថាធិប្បាយរបស់ការិយាល័យអង្គការសហប្រជាជាតិស្ដីពីឧក្រិដ្ឋកម្ម និងគ្រឿងញៀនទៅលើគោលការណ៍ Bangalore ("ការអត្ថាធិប្បាយរបស់ UNODC") ពន្យល់ទាក់ទងទៅនឹងគោលការណ៍ និងការអនុវត្តនេះថា ការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* ត្រូវតែជៀសវៀងហើយថាបើសិនជាចៅក្រមទទួលការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* ភាគីម្ខាងទៀតដាច់ខាតត្រូវតែទទួលការជូនដំណឹង ហើយកំណត់ត្រាតុលាការត្រូវធ្វើឡើងអោយស្របទៅតាមនោះ[23]។

---

[21] ដំណោះស្រាយរបស់ ECOSOC 2007/22 *ដែលស្វែងរកបាននៅគេហទំព័រ* http://www.un.org/ecosoc/docs/2007/Resolution%202007-22.pdf.។ គោលការណរណ៍ Bangalore មានការសិក្សាដំបូងបង្អស់ទៅលើក្រមចរិយាធម៌របស់ចៅក្រម និងមានបំណងអនុវត្តចំពោះចៅក្រមនៅទូទាំងពិភពលោក ។ ក្រុមការងារស្ដីពីចរិយាធម៌ចៅក្រម, បណ្ដាញក្រុមប្រឹក្សាយុត្តិធម៌អឺរ៉ុប Consiglio Superiore Della Magistratura នៅទំព័រ ២៥ ។

[22] ចំពោះសេចក្ដីពិស្ដារនៃដំណើរការនេះ សូមមើលអត្ថបទរបស់ក្រុមចរិតភាពតុលាការ ក្រោមចំណងជើងថាសេចក្ដីអត្ថាធិប្បាយទៅលើគោលការណ៍ Bangalore ស្ដីពីចរិយាធម៌របស់ចៅក្រៅ មីនា ២០០៧ ទំព័រ ៩-១៩ *ដែលស្វែងរកបាននៅ គេហទំព័រ* http://www.coe.int/t/dghl/cooperation/ccje/textes/BangalorePrinciplesComment.PDF.។

[23] ការិយាល័យអង្គការសហប្រជាជាតិស្ដីពីឧក្រិដ្ឋកម្ម និងគ្រឿងញៀន សេចក្ដីអត្ថាធិប្បាយទៅលើគោលការណ៍ Bangalore ស្ដីពីចរិយាធម៌របស់ចៅក្រម, ខែកញ្ញា ឆ្នាំ ២០០៧ កថាខណ្ឌ ៦៤ អាចស្វែងរកបាននៅ http://www.unodc.org/documents/corruption/publications_unodc_commentary-e.pdf ("សេចក្ដីអត្ថាធិប្បាយលើគោលការណ៍ Bangalore របស់ UNODC")។ សេចក្ដីអត្ថាធិប្បាយរបស់ UNODC ថ្លែងបន្ថែមទៀតទាក់ទងនឹងគុណតម្លៃទី៤ "ភាពត្រឹមត្រូវ និងការលេចចេញមកខាងក្រៅនៃភាពត្រឹមត្រូវ ទាំងផ្នែកវិជ្ជាជីវៈ និងផ្នែកឯកជន គឺជាតុមានសារៈសំខាន់នៃជីវិតរបស់ចៅក្រម។ អ្វីដែលបង្កើតជាបញ្ហាច្រើននោះគឺមិនមែនជាអ្វីចៅក្រម ត្រូវធ្វើ ឬមិនត្រូវធ្វើនោះឡើយ ប៉ុន្តែជាអ្វីដទៃទៀតកិតថាចៅក្រមបានធ្វើ ឬចៅក្រមប្រហែលជាបានធ្វើ។ <u>ឧទាហរណ៍ ចៅក្រមម្នាក់និយាយជាសម្ងាត់ និងក្នុងរយៈពេលវែងជាមួយគូវិវាទម្នាក់ នៅក្នុងរឿងក្ដីរង់ចាំការសម្រេចសេចក្ដីនឹងធ្វើលេចឡើងថាគូវិវាទនោះកំពុងទទួលបាននូវអត្ថប្រយោជន៍ សូម្បីតែថាការសន្ទនាគ្នានោះគឺគ្មានទាក់ទងអ្វីសោះនឹងរឿងក្ដីក៏ដោយ</u>។ ចាប់ពីពេលដែលសាធារណៈជនរំពឹងថាចៅក្រមនឹងមានបទដ្ឋានចរិយាធម៌ខ្ពស់ ចៅក្រមនោះត្រូវសួរនូវសំណួរថា "តើរឿងនេះនឹងទៅជាយ៉ាងណាដូចម្ដេចនៅក្រសែភ្នែករបស់សាធារណៈជន?"។ ដូចខាងលើ កថាខណ្ឌ ១១១។

16. ថ្វីត្បិតតែក្រមសីលធម៌របស់ចៅក្រមនៅ អវតក មិនមានបញ្ញត្តិដែលហាមប្រាមជាពិសេសនូវការប្រាស្រ័យទាក់ទងជាមួយ*ភាគីតែម្ខាង* ដែលកើតឡើងគ្មានការយល់ព្រម ឬលាតត្រដាងប្រាប់ដល់ភាគីដទៃទៀតឡើយ។ ប៉ុន្តែ ការហាមប្រាមបែបនេះអាចត្រូវបានគេទាញការសន្និដ្ឋានចេញពីការដែលថាវាត្រូវបានគេអនុម័តដើម្បីបញ្ចូល "ទាំងនិយាមជាតិ និងអន្តរជាតិ[24]" ដែលហាមប្រាមការប្រាស្រ័យទាក់ទងបែបនេះ[25] ហើយតាមរយៈមាត្រា ១ និង មាត្រា ២ នៃក្រមសីលធម៌របស់អវតក [26]។

---

[24] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក បុព្វកថា

[25] *សូមមើល ជាឧទាហរណ៍* សេចក្តីអត្ថាធិប្បាយលើគោលការណ៍ Bangalore របស់ UNODC កថាខណ្ឌ ៦៤។ សីលធម៌ និងចរិយាធម៌វិជ្ជាជីវៈចៅក្រមនៅកូសូវ៉ូ ដែលចែងនៅក្នុងផ្នែក III (ក) (៧) ថា "លើកលែងតែក្នុងករណីដែលចែងដោយច្បាប់ត្រូវជៀសវៀង និងមិនទទួលយកនូវការទំនាក់ទំនងជាមួយ*ភាគីតែម្ខាង*។ នៅពេលកើតឡើងនូវការទំនាក់ទំនងបែបនេះ ចៅក្រមត្រូវតែលាតត្រដាងភ្លាមៗនូវព័ត៌មានពាក់ព័ន្ធទៅភាគីដទៃទៀតនិងបើសិនជាអាច អញ្ជើញពួកគេឲ្យចូលរួម" *អាចស្វែងរកបាននៅគេហទំព័រ* http://www.courtethics.org/Kosovo.pdf ។ ធម្មនុញ្ញជាសកលរបស់ចៅក្រម ដែលត្រូវបានព្រាងដោយមានការផ្តល់យោបល់ពីចៅក្រមនានាលើពិភពលោក ហើយត្រូវបានអនុម័តយល់ព្រមជាឯកច្ឆ័នដោយអ្នកតំណាងដែលចូលរួមក្នុងកិច្ចប្រជុំនៃក្រមមជ្ឈិមនៃសមាគមអន្តរជាតិសម្រាប់ចៅក្រម នៅទីក្នុងតៃប៉ិ (តៃវ៉ាន់) នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩។ *សូមមើលផងដែរ* មគ្គុទេសន៍សម្រាប់ចរិយាធម៌ចៅក្រមរបស់តុលាការអង់គ្លេស និង Wales ដែលត្រូវបានធ្វើវិសោធនកម្មកាលពីខែ មីនា ឆ្នាំ ២០០៨ ដែលចែងនៅក្នុងផ្នែក ២.១ ថា "ចៅក្រមត្រូវតែរក្សាឲ្យបាននូវចរិយារបស់ខ្លួន ទោះក្នុងវិស័យឯកជន ឬសាធារណៈក៏ដោយ ដែលមិនធ្វើខូចដល់ឯករាជ្យភាពរបស់ស្ថាប័នខ្លួន ឬឯករាជ្យភាពរបស់ខ្លួន ឬការសម្តែងចេញជាសាធារណៈនៃឯករាជ្យភាព" *អាចស្វែងរកបាននៅគេហទំព័រ* http://www.abanet.org/judicialethics/ABA_MCJC_approved.pdf (គូសបញ្ជាក់បន្ថែម)។ វិធាន ២.៩ នៃ ក្រមចរិយាធម៌ចៅក្រមគំរូរបស់គណៈមេធាវីអាមេរិក ហាមប្រាមការប្រាស្រ័យទាក់ទង*ជាមួយភាគីតែម្ខាង* លើកលែងតែក្នុងស្ថានភាពមួយដែលត្រូវបានគ្រប់គ្រងតឹងរឹង, មានព្រំដែន និងជាក់លាក់មួយចំនួន៖

(ក) ចៅក្រមមិនត្រូវផ្តួចផ្តើម, អនុញ្ញាត ឬពិចារណាការប្រាស្រ័យទាក់ទង*ជាមួយភាគីតែម្ខាង* ឬពិចារណាការប្រាស្រ័យទាក់ទងផ្សេងទៀត ដែលធ្វើទៅកាន់ចៅក្រមដោយមិនមានវត្តមានរបស់ភាគីផ្សេងទៀត ឬមេធាវីរបស់ពួកគេទាក់ទិននឹងបញ្ហាដែលកំពុងរង់ចាំការសម្រេច ឬជិតឈានដល់ការសម្រេច លើកលែងករណីដូចខាងក្រោម៖

(១) នៅពេលដែលកាលៈទេសៈតម្រូវ ការប្រាស្រ័យទាក់ទង*ជាមួយភាគីម្ខាង* ក្នុងគោលបំណងដើម្បីកំណត់កាលបរិច្ឆេទ, កិច្ចការរដ្ឋបាល ឬបញ្ហាទាន់ហាន់ផ្សេងទៀត <u>ដែលមិនដោះស្រាយនូវខ្លឹមសារ</u> ត្រូវបានអនុញ្ញាត ដោយហេតុថា៖

(ក) ចៅក្រមមានហេតុផលជឿជាក់ថាគ្មានភាគីណាមួយកេងយកចំណេញដំណើរការនីតិវិធី កិច្ចការរដ្ឋបាល ឬយុទ្ធវិធី ដែលបណ្តាលមកពីការប្រាស្រ័យទាក់ទង*ជាមួយភាគីតែម្ខាង* ហើយនិង

(ខ) ចៅក្រមត្រូវត្រៀមរៀបចំធ្វើការជូនដំណឹងភ្លាមៗដល់គូភាគីទាំងអស់ អំពីខ្លឹមសារនៃការប្រាស្រ័យទាក់ទង*ជាមួយភាគីម្ខាងនេះ*ហើយផ្តល់ឱកាសដល់ភាគីទាំងនោះដើម្បីឆ្លើយតប...

### ខ. ការដកខ្លួន និងបណ្ដឹងដិតចិត្តចំពោះចៅក្រម

17. សិទ្ធិទទួលការជំនុំជម្រះក្តីដោយឯករាជ្យ និងមិនលំអៀង ជាធាតុផ្សំដ៏សំខាន់នៃសិទ្ធិជាមូលដ្ឋានទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ វិធាន ៣៤ (២) ដែលឆ្លុះបញ្ចាំងអំពីសិទ្ធិទទួលការជំនុំជម្រះក្តីដោយឯករាជ្យ និងមិនលំអៀង ចែងថា[27]៖

> ភាគីអាចធ្វើបណ្ដឹងដិតចិត្តចំពោះសហចៅក្រមស៊ើបអង្កេត ឬចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឲ្យមានភាពលំអៀង។

18. យុត្តិសាស្ត្រនៃអ.វ.ត.ក ដែលបកស្រាយពាក់ព័ន្ធនឹងវិធាននេះ បានអនុម័តលក្ខណៈវិនិច្ឆ័យមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និងចែងថា៖

> ចៅក្រមរូបរូបត្រូវបានចាត់ទុកថាលម្អៀង ប្រសិនបើគេរកឃើញអត្ថិភាពនៃភាពលម្អៀងនោះពិតប្រាកដមែន។

---

(៥) ចៅក្រម អាចផ្តួចផ្តើម, អនុញ្ញាត ឬពិចារណាលើការប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង* នៅពេលវាត្រូវបានអនុញ្ញាតជាក់លាក់ដោយច្បាប់ឲ្យធ្វើដូច្នេះបាន។

(**៦**) បើសិនជាចៅក្រមទទួលបានដោយចៃដន្យនូវការប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង* ដែលគេហាមឃាត់ ដែលទាក់ទងនឹងខ្លឹមសារនៃបញ្ហាមួយ ចៅក្រមត្រូវត្រៀមរៀបចំធ្វើការជូនដំណឹងភ្លាមៗដល់ភាគីទាំងអស់អំពីខ្លឹមសារនៃការប្រាស្រ័យទាក់ទង *ជាមួយភាគីតែម្ខាង*នេះ ហើយផ្តល់ឱកាសទាំងនោះដើម្បីឆ្លើយតប។

[26] *សូមមើល* មាត្រា ១ និងមាត្រា ២ នៃក្រមសីលធម៌របស់អ.វ.ត.ក ដែលចែងថា៖ “មាត្រា១ គោលការណ៍ឯករាជ្យភាពរបស់តុលាការ៖ ១. ចៅក្រមត្រូវរក្សាឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន។ ២. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន។ មាត្រា២ គោលការណ៍អនាគតិ៖ ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង នឹងត្រូវធានាពីការបង្ហាញភាពមិនលំអៀងនោះ ក្នុងការបំពេញមុខនាទីរបស់ខ្លួន។ ២. ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ថាមានជម្លោះផលប្រយោជន៍កើតឡើង”។

[27] *សូមមើល* មាត្រា ១៤ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ *រឿងក្តី* រដ្ឋអាជ្ញា *Karemera* តទល់នឹង ICTR-98-44-T និងអ្នកដទៃ។ សេចក្តីសម្រេចលើបណ្ដឹងដិតចិត្តរបស់ Karemera ចំពោះចៅក្រមជំនុំជម្រះ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ៨ (“ដីកាសម្រេច Karemera ឆ្នាំ ២០០៤”)

អត្ថិភាពនៃភាពលម្អៀងស្តែងចេញឲ្យឃើញ ក្នុងករណីដែល៖

- ចៅក្រមរូបនោះជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិដែលបានមកពីរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះនឹងនាំឲ្យមានការជួយជំរុញដល់ហេតុនៃរឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធនឹងភាគីណាមួយក្នុងរឿងក្តីនោះ[28]។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះត្រូវតែដកចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
- កាលៈទេសៈបណ្តាលឲ្យអ្នកសង្កេតការដែលឥតលម្អៀង និងទទួលបានព័ត៌មានត្រឹមត្រូវអាចយល់បានដោយសមហេតុផល ថាមានភាពលម្អៀង[29]។

---

[28] លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានអនុម័ត និងបកស្រាយដោយតុលាការអន្តរជាតិដទៃទៀត ជាជាងដោយដោយតុលាការ ICTY ។ សូមមើល ឧទាហរណ៍ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៤១(២)(ក) និងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាន៣៤(១) (អានផ្ទួបគ្នាជាមួយនឹងឃ្លាថា តម្រូវឲ្យប្រកាសជិតចិត្តចៅក្រមមួយរូបណា ដែលភាពលម្អៀងរបស់គាត់ "អាចមានហេតុផលសមស្របណាមួយឲ្យគេមានសង្ស័យ" រួមទាំងការពាក់ព័ន្ធពីមុនណាមួយជាមួយ ឬផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងករណីនោះ ទំនាក់ទំនងណាមួយជាមួយនឹងគូភាគី ឬតំណែងដែលគាត់មាន ឬគំនិតដែលបញ្ចេញមិនស៊ីគ្នានឹងភាពអនាគតិរបស់គាត់)។ វិធាន១៥នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTY និង ICTR មានខ្លឹមសារដូចគ្នា។ សូមមើលបន្ថែម រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Norman* នៅតុលាការ SCSL-2004-14 សេចក្តីសម្រេចស្តីពីញត្តិសុំឲ្យចៅក្រម Winter ដកខ្លួនចេញពីការពិភាក្សាសម្រេច នៅក្នុងញត្តិបឋមស្តីពីការរើសទាហានកូនក្មេង ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ២៨។

[29] សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជិតចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើផ្សេងពាក់ព័ន្ធផ្សេងៗទៀត ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E5/3 ("សេចក្តីសម្រេចលើករណីចៅក្រម *និល ណុន*") កថាខណ្ឌ ៦។ *សូមមើលផងដែរ* សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជិតចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល រង់ចាំបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងករណី នួន ជា ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារលេខ C11/29 ("*សាលដីកាលើករណីចៅក្រម ន័យ ថុល*") កថាខណ្ឌ២០-២១ (ប្រៀបធៀប "អ្នកសង្កេតដែលមិនលម្អៀង" ជាមួយនឹង "បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ដោយមានការយល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលម្អៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីយកិច្ចមួយក្នុងចំណោមករណីយកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើង")។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Furundžija*, IT-95-17/1-A សាលក្រម ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ ១៨៩។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Sesay* *និងអ្នកផ្សេងទៀត* SCSL-04-15-T-909 សេចក្តីសម្រេចស្តីពីញត្តិរបស់ Sesay និង Gbao សុំឲ្យចៅក្រម Bankole Thompson ដកខ្លួនចេញដោយស្ម័គ្រចិត្តពីសំណុំរឿង RUF ឬសុំប្តឹងជិតចិត្តគាត់ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ៥១។ សេចក្តីសម្រេច *Karemera* ឆ្នាំ ២០០៤ កថាខណ្ឌ៩។

19. យុត្តិសាស្ត្រនៃ អ.វ.ត.ក កត់សម្គាល់បន្ថែមទៀតថា បណ្តឹងជំទាស់ចៅក្រមតម្រូវឲ្យប្តឹងបានចំពោះតែចៅក្រមជាក់លាក់ណាម្នាក់ ដែលកំពុងដោះស្រាយរឿងក្តីជាក់លាក់ណាមួយប៉ុណ្ណោះ មិនមែនប្តឹងជំទាស់ចំពោះករណីទូទៅនោះទេ[30]។

**គ. វិធានក្រមសីលធម៌ដែលត្រូវអនុវត្តដោយសហព្រះរាជអាជ្ញាអន្តរជាតិ**

20. កថាខណ្ឌ៣០១(ក) (ii) និង (iii) នៃក្រមសីលធម៌នៃគណៈមេធាវីនៅអង់គ្លេស និងវេល ចែងថា មេធាវីមិនត្រូវ "(ក)ចូលរួមក្នុងការប្រព្រឹត្តិមិនថាតើក្នុងការស្វែងរកវិជ្ជាជីវៈរបស់ខ្លួនឬ ផ្សេងពីនេះ ដែល ... (ii) អន្តរាយដល់រដ្ឋបាលយុត្តិធម៌ ឬ (iii) ទំនងបន្ថយទំនុកចិត្តរបស់សាធារណៈមកលើវិជ្ជាជីវៈផ្នែកច្បាប់ ឬរដ្ឋបាលនៃយុត្តិធម៌ ឬនាំមកនូវឈ្មោះអាក្រក់ដល់វិជ្ជាជីវៈផ្នែកច្បាប់"។

**ឃ. ភារកិច្ចនៃការលាតត្រដាងរបស់ចៅក្រម Cartwright**

21. កថាខណ្ឌ៨៥ និង៨៦នៃគោលការណ៍សីលធម៌ចៅក្រមរបស់ប្រទេសនូវែលសេឡង់ ចែងចំៗថា៖[31]

> ៨៥ ... ការលាតត្រដាងនូវបញ្ហាណាមួយដែលអាចឲ្យកើតមាននូវការជំទាស់ គួរត្រូវបានអនុវត្ត បើទោះជាចៅក្រមបានទស្សនៈបឋមមួយថា គ្មានមូលដ្ឋានសម្រាប់បណ្តឹងជំទាស់ក្តី។ អាចថាមានកាលៈទេសៈ ដែលចៅក្រមមិនដឹង ដែលអាចត្រូវបានលើកឡើងដោយភាគីទាំងអស់ ជាលទ្ធផលនៃការលាតត្រដាងបែបនោះ។

---

សេចក្តីសម្រេចស្តីពីពាក្យសុំរបស់លោក El Sayed សុំប្តឹងជំទាស់ចៅក្រម Riachy ពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អនុលោមតាមវិធាន២៥ STL President (CH/PRES/2010/08) ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ១៩ ។

[30] វិធានផ្ទៃក្នុង៣៤(២)។ សេចក្តីសម្រេចលើករណីចៅក្រម និល ណុន កថាខណ្ឌ៧,៨ និង១៧។ សេចក្តីសម្រេចលើករណីចៅក្រម ន័យ ធុល កថាខណ្ឌ៩-១១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត លេខ* IT-96-21-T សេចក្តីសម្រេចរបស់ the Bureau ស្តីពីពាក្យសុំប្តឹងជំទាស់ចៅក្រមមួយចំនួន ដោយអនុលោមតាមវិធាន១៥ ឬអាចជំនួសដោយជម្រើសនៃការសុំដកខ្លួនដោយខ្លួនឯងពីសំណាក់ចៅក្រមទាំងនោះវិញក៏បាន ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៩ កថាខណ្ឌ៨ -៩ (ភាពខុសគ្នារវាងសេចក្តីសម្រេចផ្នែករដ្ឋបាល ទី១គឺត្រង់ថាតើជនម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីជាចៅក្រមបានដែរ ឬយ៉ាងណា ទី២អំពីពាក្យបណ្តឹងសុំជំទាស់ចៅក្រមពាក់ព័ន្ធនឹងភាពលម្អៀងរបស់ចៅក្រមរូបនោះ ទាក់ទិន*ករណីជាក់លាក់មួយ*)។

[31] គោលការណ៍សម្រាប់ក្រមសីលធម៌ចៅក្រមរបស់ប្រទេសញូវែលហ្សេឡង់ ដែលអាចមើលបាននៅ http://www.courtsofnz.govt.nz/business/guidelines/guidelines-for-judicial-conduct/Guidelines-for-Judicial-Conduct-June-2011.pdf (គូសបញ្ជាក់បន្ថែម)។

## ង. កាតព្វកិច្ចនៃវិរិយភាពទាន់ពេលវេលារបស់មេធាវីការពារក្តី

22. វិធាន៣៤(៣)ចែងថា ការអនុវត្តនូវបណ្តឹងជំទាស់សុចិត្តគួរត្រូវបានដាក់ ភ្លាមៗនៅពេលដែលភាគីទទួលបានព័ត៌មានអំពីមូលដ្ឋាននៃបញ្ហា។ មេធាវីការពារក្តីត្រូវបានតម្រូវឲ្យបំពេញមុខងារជាមួយនឹងវិរិយភាពទាន់ពេលវេលា ក្នុងការការពារផលប្រយោជន៍របស់កូនក្តីខ្លួន[32]។

## IV. ទន្លឹករណ៍

### ក. ការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងចៅក្រម Cartwright និង លោក Cayley មានបញ្ហា

23. អត្ថិភាពនៃភស្តុតាង *បឋម* បង្ហាញថាការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង ដែលបានកើតឡើងរវាងចៅក្រមមួយរូបនៃអង្គជំនុំជម្រះសាលាដំបូង និងសហព្រះរាជអាជ្ញាអន្តរជាតិ។ ជាចំណែកវិរិយភាពទាន់ពេលវេលារបស់មេធាវីការពារក្តី យើងខ្ញុំត្រូវតែស្វែងរកការលាតត្រដាងពីសំណាក់លោក Cayley និងសេចក្តីថ្លែងការណ៍មួយពីសំណាក់ចៅក្រម Cartwright ដើម្បីកំណត់ថាតើមានមូលដ្ឋានសម្រាប់

---

[32] វចនានុក្រមច្បាប់ *Black's Law Dictionary* កំណត់និយមន័យវិរិយភាពថាជា "វិរិយភាពដែលត្រូវបានរំពឹងទុកដោយសមហេតុផល និងអនុវត្តយ៉ាងសាមញ្ញដោយបុគ្គលម្នាក់ ដែលស្វែងរកបំពេញទៅតាមតម្រូវការផ្នែកច្បាប់ ឬដើម្បីអនុវត្តកាតព្វកិច្ច" វចនានុក្រមច្បាប់ BLACK'S LAW DICTIONARY 468 (បោះពុម្ពលើកទី៧ ឆ្នាំ ១៩៩៩)។ តុលាការ ICTY បានចែងថា គោលបំណងនៃដំណើរផ្តល់ជនជាប់ចោទនូវសិទ្ធិជាក់លាក់មួយចំនួនក្រោមលក្ខន្តិកៈតុលាការ ICTY "គឺថា ជនជាប់ចោទគួរអនុវត្តវិរិយភាពក្នុងការប្រើប្រាស់សិទ្ធិ"។ ចៅក្រម RICHARD MAY & MARIEKE WIERDA ភស្តុតាងព្រហ្មទណ្ឌអន្តរជាតិ ៣០៦ (Transnational Publishers Inc. ឆ្នាំ ២០០២) *ពិភាក្សាអំពីរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះការពន្យាររយៈពេលកំណត់ និងការទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៨។ ក្នុងបរិបទនៃការអនុវត្ត ក្នុងការបើកដេញដោលរឿងក្តីមួយឡើងវិញ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានចែងថា ការពិចារណាបឋមរបស់អង្គជំនុំជម្រះមួយ ក្នុងការកំណត់ការអនុវត្តមួយសម្រាប់បើកដេញ ដោលរឿងក្តីមួយឡើងវិញ ដើម្បីអនុញ្ញាតឲ្យមានការទទួលយកភស្តុតាងថ្មីៗ គឺជាសំណួរថាតើ ជាមួយនឹងវិរិយភាពសមហេតុផល ឬអត់ ដែលភស្តុតាងអាចត្រូវបានកំណត់ និងបង្ហាញក្នុងរឿងក្តីនៃភាគីដែលធ្វើការអនុវត្តនោះ។ ប្រសិនបើវាមិនត្រូវបានរកឃើញជាមួយនឹងការអនុវត្តនៃវិរិយភាពទាន់ពេលវេលាទេនោះ អង្គជំនុំជម្រះអាចអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ថាតើត្រូវទទួលយកភស្តុតាង ឬអត់។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Delalić និងអ្នកផ្សេងទៀត* IT-96-21-A សាលដីកា លើ បណ្តឹង ឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៨៣។

ប៉ិងជិតចិត្តចំពោះចៅក្រម Cartwright ឬអត់ និង/ឬ ស្វែងរកវិធានការដាក់វិន័យសមស្របប្រឆាំងនឹងលោក Cayley។

### *ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួនឡើយ*[33]

24. យោងតាមច្បាប់ស្តីពីការបង្កើត អវតក ចៅក្រម "ត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួលឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយឬពីប្រភពណាមួយផ្សេងទៀតឡើយ"[34]។ យោងតាមលោក Rosandhaug ចៅក្រម Cartwright បានចូលរួមក្នុងការប្រជុំផ្សេងៗជាមួយនឹងលោក Cayley ពិភាក្សាបញ្ហារដ្ឋបាលនានាដែលពុំប៉ះពាល់នឹងសំណុំរឿង០០២ឡើយ។ នេះហាក់ដូចជាពុំសមហេតុផលសោះឡើយ។ វាមិនពិតទេដែលសន្មតថាបញ្ហាដូចបានលើកឡើងគឺជាបញ្ហា "រដ្ឋបាល" ដែលមានលក្ខណៈធូរស្រាលដោយសារតែចំណងជើងវា ។ ចៅក្រម Cartwright គឺពុំពាក់ព័ន្ធ (ឬយ៉ាងហោចណាស់ពុំគួរពាក់ព័ន្ធ) នឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០១ ឬការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ឡើយ។ បើពិនិត្យលើអង្គហេតុដែលមានទាំងអស់ ចៅក្រម Cartwright ពុំមែនចូលរួមការប្រជុំទាំងនេះ (និងប្រហែលជាការប្រជុំផ្សេងៗទៀត) ជាសមាជិក ឬតំណាងនៃគណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC")[35] ឡើយ ហើយក៏គ្មានការបង្ហាញជាមូលដ្ឋានផ្នែកច្បាប់ចំពោះការប្រជុំទាំងនេះដែរ ។ ពុំមានចៅក្រមជាតិណាម្នាក់ដឹងឮអំពីបញ្ហា "រដ្ឋបាល" ទាំងនេះឡើយ។

25. វាច្បាស់ណាស់ថាចៅក្រម Cartwright បានចូលរួមក្នុងការប្រជុំ*សម្ងាត់* ទាំងនេះក្នុងសមត្ថភាពជាចៅក្រមក្នុងសំណុំរឿង០០២ ប៉ុន្តែដោយពុំបង្ហាញអំពីអំណាចដោយគណៈកម្មាធិការរដ្ឋបាលតុលាការឡើយ។ បន្ថែមលើនេះទៀត វាច្បាស់ណាស់ថាចៅក្រម Cartwright បានពិភាក្សាបញ្ហានានាជាមួយលោក Cayley ដែលកាលពីមុន បាន និងបន្តបង្ហាញខ្លួននៅចំពោះមុខចៅក្រម Cartwright តទៅទៀតក្នុងសំណុំរឿង០០២។ ក្នុងករណីដែលការជួបប្រជុំលក្ខណៈជិតស្និត ឧទាហរណ៍នៅពេលដែលសេចក្តីសម្រេចលើបញ្ហាអង្គហេតុ ឬផ្នែកច្បាប់សំខាន់ៗអាចធ្វើឲ្យផ្អៀងតុល្យភាពទៅម្ខាងៗ វាមិនពិបាកនឹងយល់ទេថាចៅក្រមមួយរូប ដែលបានបើកផ្លូវឲ្យព្រះរាជអាជ្ញាមួយរូប ជាលទ្ធផលនៃទំនាក់ទំនង*សម្ងាត់*

---

[33] ក្រមសីលធម៌ចៅក្រមរបស់អវតក មាត្រា១(២)។

[34] ច្បាប់ស្តីពីការបង្កើតអវតក មាត្រា១០ថ្មី។

[35] *សូមមើល*វិធាន១៩។

ច្រើនលើកច្រើនសាទាំងនេះ ប្រសិនបើពុំដោយចេតនាទេនោះ នឹងធ្វើការជំនុំជម្រះលម្អៀងទៅខាងភាគីនោះ ។

26. គ្មានកំណត់ហេតុ (កំណត់ត្រា) នៃការប្រជុំទាំងនេះឡើយ ទន្ទឹមនឹងដំណើរដែលគ្មានការពេញចិត្តនឹងផ្តល់ព័ត៌មានពិស្តារ (មិនរៀបរាប់ពីការបដិសេធរបស់លោក Cayley ក្នុងការទទួលស្គាល់មូលដ្ឋានណាមួយចំពោះការចោទប្រកាន់អំពីភាពមិនត្រឹមត្រូវ និងការបន្តបដិសេធមិនឆ្លើយឲ្យចំៗនឹងសំណួរផ្សេងៗអំពីបញ្ហា)[36] ឲ្យមេធាវីការពារក្តី និងទៅលើបញ្ហាឲ្យអ្នកអង្កេតការសត្យានុម័ត រាល់មូលហេតុដែលពាក់ព័ន្ធស្វែងយល់ថា ចៅក្រម Cartwright អាចមិនបានបំពេញមុខនាទីដោយឯករាជ្យឲ្យបានគ្រប់ពេលវេលាឡើយ ក្នុងសំណុំរឿង០០២។

***ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន***[37]

27. ចៅក្រមនៅអ.វ.ត.ក មិនត្រឹមតែត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យប៉ុណ្ណោះទេ តែក៏ត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយមិនលម្អៀងផងដែរ[38]។ យោងទៅតាមមាត្រា១២៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា "អំណាចតុលាការត្រូវធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ" មាត្រា៣(៣)នៃកិច្ចព្រមព្រៀងគូសបញ្ជាក់ថា ចៅក្រម "ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និង

---

[36] *សូមមើល*ជើងទំព័រខាងក្រោម កថាខណ្ឌ៧, ១០ និង ១១។

[37] ក្រមសីលធម៌ចៅក្រមនៅអ.វ.ត.ក មាត្រា២(១)។

[38] "សញ្ញាណនៃ**អនាគតិរបស់ប្រព័ន្ធតុលាការ** ជាទិដ្ឋភាពដ៏សំខាន់មួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មានន័យថា ចៅក្រមទាំងអស់ដែលពាក់ព័ន្ធចាំបាច់ត្រូវបំពេញមុខងារដោយសត្យានុម័ត និងផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើអង្គហេតុពាក់ព័ន្ធ និងច្បាប់ជាធរមាន ដោយគ្មានភាពលម្អៀងផ្ទាល់ខ្លួន ឬគំនិតត្រៀមទុកជាមុនលើបញ្ហា និងអ្នកពាក់ព័ន្ធ និងដោយមិនតម្កល់ផលប្រយោជន៍ភាគីម្ខាងណាឡើយ"។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សិទ្ធិមនុស្សក្នុងរដ្ឋបាលនៃយុត្តិធម៌ ៖ សៀវភៅស្តីពីសិទ្ធិមនុស្សសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ជំពូក៤៖ ឯករាជ្យភាព និងភាពមិនលម្អៀងរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ១៣៩ (ឆ្នាំ ២០០៣) *អាចរកមើលបាននៅ* http://www.ohchr.org/Documents/Publications/training9chapter4en.pdf. គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ថ្លែងថា គោលការណ៍អនាគតិ "បង្កប់ន័យថា ចៅក្រមមិនត្រូវផ្តល់ទីស្នាក់អាស្រ័យដល់បុរេនិច្ឆ័យណាមួយអំពីបញ្ហា ដាក់នៅចំពោះមុខពួកគេឡើយ ហើយថា ពួកគេមិនត្រូវបំពេញមុខងារ តាមរបៀបដែលតម្កល់ផលប្រយោជន៍នៃភាគីម្ខាងឡើយ" គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្ស លិខិតលេខ. 387/1989 (រឿងក្តី *Karttunen តទល់នឹង Finland*), ឯកសារអង្គការសហប្រជាជាតិលេខ CCPR/C/46/D/387/1989 ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ទំព័រ ៧.២។

ស្មារតីខ្ពស់ មិនលំអៀង និងសុចរិត" និង "ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"។ យោងតាមវិធាន២១(១)(ក) "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និង អាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស"[39]។

28. ចៅក្រមនៅ អ.វ.ត.ក មិនអាចចូលរួមក្នុងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងជាមួយបុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញាបានឡើយ ដោយពុំបានជូនដំណឹងដល់មេធាវីការពារក្តី ។ ការប្រព្រឹត្តិនេះពុំគ្រាន់តែត្រូវបានហាមប្រាមដោយក្រមសីលធម៌ និងបទដ្ឋានវិជ្ជាជីវៈជាធរមានប៉ុណ្ណោះទេ តែវាថែមទាំងរំលោភទៅលើសិទ្ធិរបស់ភាគីផ្សេងៗផងដែរ។ តុលាការអឺរ៉ុបនៃសិទ្ធិមនុស្សបានថ្លែងថា៖

> គោលការណ៍សមភាពនៃកម្លាំងគ្រាន់តែជាលក្ខណៈពិសេសមួយនៃទស្សនទានទូលាយនៃការជំនុំជម្រះដោយយុត្តិធម៌ប៉ុណ្ណោះ ដែលក្នុងនោះក៏រួមមាន សិទ្ធិជាមូលដ្ឋាន ដែលដំណើរការនីតិវិធីព្រហ្មទណ្ឌគួរត្រូវគោរពគោលការណ៍ចំពោះមុខផងដែរ... សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីតទល់គ្នា មានន័យថា ក្នុងរឿងក្តីព្រហ្មទណ្ឌមួយ គឺទាំងភាគីរដ្ឋអាជ្ញា និងមេធាវីការពារក្តីត្រូវទទួលបានឱកាសដឹងឮ និងមានមតិយោបល់ទៅលើការអង្កេតផ្សេងៗ ដែលបានដាក់ និងភស្តុតាងដាក់ដោយភាគីម្ខាងទៀត[40]។

29. បើទោះជាអាចមានករណីខ្លះ ដែលការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាងមួយចំនួនអាចពុំមានលក្ខណៈអន្តរាយ ឬប៉ះពាល់ដល់ភាគីមួយ គួររំលឹកពាក្យពេចន៍របស់ចៅក្រម Robinson អតីតប្រធាននៃតុលាការ ICTY: " [ទំនាក់ទំនងការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង] ត្រូវបានធានា ល្អិតល្អន់ដែលមានការលោតត្រដាងដល់ភាគីម្ខាងទៀត ឬភាគីទាំងអស់ក្នុងដំណើរការនីតិវិធីអំពីព័ត៌មាននានាកើតចេញពីការអនុវត្តបៀបនេះ ឬអំពីអង្គហេតុក្នុងការអនុវត្តបែបនេះ នឹងទំនងជាប៉ះពាល់ដោយអយុត្តិធម៌ទៅលើភាគីដែលអនុវត្តសកម្មភាពបែបនេះ ឬបុគ្គល ឬមនុស្សខ្លះ ដែលជាប់ពាក់ព័ន្ធ ក្នុង ឬទាក់ទិននឹង

[39] គូសបញ្ជាក់បន្ថែម។

[40] *រឿងក្តី Brandstetter តទល់នឹង ប្រទេសអូទ្រីស* ECHR សាលក្រម ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩១ កថាខណ្ឌ៦៦-៦៧ (គូសបញ្ជាក់បន្ថែម)។

ការអនុវត្តនោះ”[41]។ ក្នុងស្ថានភាពនេះ ការប្រាស្រ័យទាក់ជាមួយតែភាគីម្ខាងមិនត្រូវបានធានាឡើយ ដោយសារមេធាវីការពារក្តីទទួលរងនូវព្យសនកម្មពីជំនួបរវាងចៅក្រម Cartwright និងលោក Cayley ពោលគឺ ដោយពុំយកចិត្តទុកដាក់ថាតើជំនួបទាំងនោះកើតមានឡើងដោយមានវត្តមានអ្នកដទៃនោះឡើយ។ ការប្រព្រឹត្តិរបស់ចៅក្រម Cartwright គួសបញ្ជាក់ថារូបគាត់ចូលរួមក្នុងបញ្ហានានាដែលពុំគ្រាន់តែហួសពីអាណត្តិរបស់គាត់ក្នុងនាមជាចៅក្រមក្នុងអង្គជំនុំជម្រះសាលាដំបូងនៃអវតកប៉ុណ្ណោះទេ ហើយថែមទាំងប៉ះពាល់ដោយផ្ទាល់ទៅលើចំណាត់ការផ្នែករដ្ឋបាលប្រកបដោយត្រឹមត្រូវក្នុងសំណុំរឿង០០២ទៀតផងដែរ។

***គោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនេះត្រូវចាត់ទុកជាសេចក្តីណែនាំស្តីពីបទដ្ឋានសីលធម៌ជាសារវ័ន្ត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន***[42]

30. វាពុំគ្រាន់តែបញ្ជាក់ច្បាស់ថាចៅក្រម Cartwright បានរំលោភភារកិច្ចរបស់គាត់ក្នុងការបំពេញមុខងារចៅក្រមក្នុងសំណុំរឿង០០២ ដោយឯករាជ្យ និងមិនលម្អៀងប៉ុណ្ណោះទេ តែការធ្វើបែបនេះវាក៏គួសបញ្ជាក់ថាលោកស្រីចៅក្រមបានរំលោភកាតព្វកិច្ចក្រមសីលធម៌ដទៃទៀត។ មាត្រា៩នៃក្រមសីលធម៌កម្ពុជា និងក្រមសីលធម៌តុលាការអន្តរជាតិ និងជាតិផ្សេងៗទៀត ហាមប្រាមយ៉ាងច្បាស់មិនឲ្យមានការប្រាស្រ័យទាក់ជាមួយតែភាគីម្ខាងរវាងចៅក្រម និងភាគីមួយ ត្បិតវាបណ្តាលឲ្យកើតមានភាពមិនត្រឹមត្រូវ និងភាពលម្អៀង[43]។

***ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និងដោយសេចក្តីសុចរិតទៀងត្រង់តាមការិយាល័យរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ***[44]

---

[41] *រឿងក្តី រាជអាជ្ញា តទល់នឹង Simić និងអ្នកផ្សេងទៀត* IT-95-9-PT សេចក្តីសម្រេចស្តីពី ១)ការអនុវត្តដោយ Stevan Todorović ក្នុងការបើកដេញដោលឡើងវិញលើ សេចក្តីសម្រេច ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩ ២)ញត្តិរបស់ ICRC ក្នុងការបើកដេញដោលឡើងវិញលើដីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ និង ៣)លក្ខខណ្ឌសម្រាប់ការចូលមើលសម្ភារៈ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០០ កថាខណ្ឌ ៣៩ (គូសបញ្ជាក់បន្ថែម)។

[42] ក្រមសីលធម៌ចៅក្រមនៅអ.វ.ត.ក មាត្រា៩(១)។

[43] ចៅក្រមអន្តរជាតិមិនមានសិទ្ធិច្រើនជាងចៅក្រមជាតិក្នុងការប្រាស្រ័យទាក់ទងតែជាមួយភាគីម្ខាងនោះទេ ។ មាត្រា១២នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ចែងថា ចៅក្រម [ដោយពុំគិតអំពីប្រទេសកំណើត] មានឋានៈ និងលក្ខខណ្ឌការងារស្មើៗគ្នា។

[44] ក្រមសីលធម៌ចៅក្រមនៅអ.វ.ត.ក មាត្រា៣(១)។

31. "ភាពសមរម្យ និងការបង្ហាញអោយឃើញពីភាពសមរម្យ មានសារៈសំខាន់ខ្លាំងណាស់ចំពោះការអនុវត្តនូវរាល់សកម្មភាពរបស់ចៅក្រមមួយរូប"[45]។ ការខកខានមិនបានធ្វើការលាតត្រដាង ឬសេចក្តីថ្លែងការណ៍ណាមួយ អនុលោមតាមសំណើនេះ ដោយចូលរួមក្នុងជំនួបឯកជនជាមួយលោក Cayley និងអ្នកផ្សេងៗទៀត ដែលគេស្គាល់ឈ្មោះ និងមិនស្គាល់ឈ្មោះ (ឬគ្រាន់តែពួកគេពីរនាក់តទល់) ចៅក្រម Cartwright បង្ហាញនូវការកើតឡើងនៃភាពលម្អៀង ពោលគឺប្រសិនបើពុំមែនជាភាពលម្អៀងជាក់ស្តែង គឺ ការឃោគយល់អនុគ្រោះដល់ការិយាល័យសហព្រះរាជអាជ្ញា។ បរិយាកាសសម្ងាត់ និងប្រញាប់ប្រញាល់ ដែលការប្រជុំ*សម្ងាត់*ទាំងនោះបានប្រព្រឹត្តិទៅ និងភាពរួញរារហូតមកទល់បច្ចុប្បន្នក្នុងការលាតត្រដាងព័ត៌មាន ដែលយើងខ្ញុំស្នើសុំកំណត់លក្ខណៈជាក់ស្តែងនៃជំនួបទាំងនោះ ពុំអាចធ្វើបានទេតែវានាំឲ្យមានសេចក្តីសន្និដ្ឋានផ្សេងៗ។ ការប្រព្រឹត្តិរបស់ចៅក្រម Cartwright ហាក់ដូចជាផ្ទុយទៅនឹងសិទ្ធិដែលត្រូវបានធានាដល់លោក អៀង សារី និងជនជាប់ចោទផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា១២៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣(៣)នៃកិច្ចព្រមព្រៀង មាត្រា១០ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន២១(១)(ក)នៃវិធានផ្ទៃក្នុង។

32. ការខកខានមិនបានធ្វើការលាតត្រដាង ឬសេចក្តីថ្លែងការណ៍ណាមួយ អនុលោមតាមសំណើនេះក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យរបស់អ.វ.ត.ក ចំពោះបណ្តឹងជិតចិត្តចំពោះចៅក្រម អ្នកអង្កេតឯករាជ្យប្រកបដោយសុភវិនិច្ឆ័យ មិនអាច ប៉ុន្តែយល់ប្រកបដោយសុភវិនិច្ឆ័យនូវភាពលម្អៀង[46]។ ការសន្មតជាមុនណាមួយនៃភាពមិនលម្អៀង[47] នឹងត្រូវបានគ្របលុបដោយការរំលោភបំពានលើក្រមសីលធម៌ចៅក្រម ដែលប៉ះពាល់ផ្ទាល់ទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ។ ការប្រព្រឹត្តិរបស់ចៅក្រម Cartwright ទំនងនឹងបណ្តាលឲ្យ "បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ ដោយមានការយល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្តីថ្លៃថ្នូរ និងភាពមិនលម្អៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិគឺជាករណីយកិច្ចមួយក្នុងចំណោមករណីយកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រ

---

[45] ក្រុមសុច្ចរិតភាពតុលាការ បទអធិប្បាយស្តីពី គោលការណ៍នៃការប្រព្រឹត្តិរបស់តុលាការ Bangalore ចុះខែ មីនា ឆ្នាំ ២០០៧ ទំព័រ ៧៩ អាចរកមើលបាននៅ
http://www.coe.int/t/dghl/cooperation/ccje/textes/BangalorePrinciplesComment.PDF.

[46] *សូមមើលជើងទំព័រ២៨។*

[47] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija,* IT-95-17/1-A សាលក្រម ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ១៩០-១៩៧។

លើកតម្កើង" ដើម្បីឲ្យយល់បានអំពីភាពលម្អៀងក្នុងស្ថានភាពនេះ។ ការប្រព្រឹត្តិរបស់ចៅក្រម Cartwright មានលក្ខណៈកាន់តែធ្វើឲ្យខ្វល់ខ្វាយថែមទៀត នៅពេលពិចារណាថាវាជាភារកិច្ចរបស់លោកស្រី ដែលត្រូវប្រកាន់យកនូវសុចរិតភាព និងភាពមិនលម្អៀងនៅតុលាការនេះ។ ផ្ទុយទៅវិញ វាហាក់ដូចជា លោកស្រីបានបំពានកាតព្វកិច្ចរបស់គាត់ក្នុងការបំពេញមុខងារដោយឯករាជ្យ និងមិនលម្អៀង ចៀសវាងនូវទំនាក់ទំនង*សម្ងាត់* និងជូនដំណឹងដល់ភាគទាំងអស់អំពីអ្វីដែលគាត់ទទួលបានពីទំនាក់ទំនងនោះ។

### ខ. សហមេធាវីការពារក្តីស្នើសុំនូវលាតត្រដាងពីសំណាក់លោក Cayley និងការលើកទឹកចិត្តឲ្យចៅក្រម Cartwright ធ្វើសេចក្តីថ្លែងការណ៍

33. ដោយមានអង្គហេតុថា មានការទទួលស្គាល់យ៉ាងបើកចំហរនាពេលបច្ចុប្បន្ននេះថា ការប្រាស្រ័យទាក់ជាមួយតែភាគីម្ខាងបានកើតឡើង និងដោយពិចារណាថាទំនាក់ទំនងបែបនោះ បំពារបំពានទៅលើក្រមសីលធម៌កម្ពុជា ក៏ដូចជានិយាមសម្រាប់អនុវត្តន៍ក្នុងប្រទេសកំណើតរបស់លោក Cayley និងចៅក្រម Cartwright[48] វាជាការច្បាស់លាស់ណាស់ដែលថា ទាំងលោក Cayley និងចៅក្រម Cartwright ដឹងអំពីបញ្ហាដែលអាច (យ៉ាងហោចណាស់) ត្រូវបានគេអះអាងថានឹងបណ្តាលឲ្យកើតមាននូវការយល់ដឹងដោយសុភវិនិច្ឆ័យអំពីភាពលម្អៀង។ ក្នុងកាលៈទេសៈទាំងនេះ ដែលពុំមានបណ្តាលឲ្យមានភាពអាម៉ាស់ផ្ទាល់ខ្លួនដល់លោក Cayley ឬចៅក្រម Cartwright នោះការបកស្រាយបញ្ជាក់ និងការលាតត្រដាងពេញលេញអំពីលក្ខណៈពិតប្រាកដនៃទំនាក់ទំនង*សម្ងាត់*របស់ពួកគេជាអ្វីដែលយើងខ្ញុំចង់បាន ក្នុងនាមជាបញ្ហាបន្ទាន់។ នៅកម្រិតអន្តរជាតិ ក្នុង*រឿងក្តី Karemera និងអ្នកផ្សេងទៀត* ការខកខានរបស់ចៅក្រមក្នុងការលាតត្រដាងអង្គហេតុ ដែលមានតម្លៃជាភស្តុតាងនៃជំនួបគ្នាមួយ ដែលអាចប៉ះពាល់ដល់ភាពមិនលម្អៀងរបស់រូបគាត់ ត្រូវបានសម្រេចថាជាសម្ភារៈមួយចំពោះសំអាងហេតុដែលកាលៈទេសៈនោះកើតមាន ដែល "អាចដឹកនាំឲ្យអ្នកអង្កេតដែលទទួលបានព័ត៌មានគ្រប់គ្រាន់ប្រកបដោយសុភវិនិច្ឆ័យម្នាក់អាចយល់បានដោយសត្យានុម័តនូវភាពលំអៀង"[49]។ ហើយដូចសាលា

---

[48] *ដូចជើងទំព័រខាងក្រោម* កថាខណ្ឌ១៣ និង ២០។

[49] *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera,* ICTR-98-44-AR 15*bis*.2 ហេតុផលសម្រាប់សេចក្តីសម្រេចលើបណ្តឹងចាត់របៀបពាក់ព័ន្ធនឹងការបន្តដំណើរការនីតិវិធីជាមួយនឹងចៅក្រមជំនួស និងស្តីពីញត្តិរបស់ Nzirorera សុំការអនុញ្ញាតពិចារណាសម្ភារៈថ្មី ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ កថាខណ្ឌ៦៧។ ក្នុងករណីដូចគ្នានេះដែរ ប៉ុន្តែទាក់ទិនឹងការអនុវត្ត

ឧទ្ធរណ៍របស់ចក្រភពអង់គ្លេសបានសម្រេចក្នុងរឿងក្តី *Locabail (UK) Ltd.* ***តទល់នឹង*** *Bayfield Properties Ltd.* [ឆ្នាំ២000] 2 WLR 870 នៅត្រង់កថាខណ្ឌ៤៧៨-៧៩ ថា ៖

> ប្រសិនបើ ក្នុងករណីដែលមិនបណ្តាលឲ្យមានបណ្តឹងជំទាស់ជាស្វ័យប្រវត្តិ និងមិនបណ្តាលឲ្យមានភាពអាម៉ាស់ផ្ទាល់ខ្លួនចំពោះចៅក្រមទេនោះ រូបគាត់យល់ដឹងអំពីបញ្ហាដែលអាចត្រូវបាននិយាយយ៉ាងសមរម្យថា បណ្តាលឲ្យកើតមានគ្រោះថ្នាក់ជាក់ស្តែងនៃភាពលម្អៀង ជាទូទៅវាសមស្របដែលថា ការលាតត្រដាងគួរត្រូវបានធ្វើឡើងដល់ភាគី នៅមុនពេលសវនាការ។ ប្រសិនបើ ពេលនោះមានការជំទាស់ វានឹងជាភារកិច្ចរបស់ចៅក្រមក្នុងការពិចារណាលើការជំទាស់នោះ និងប្រើប្រាស់ការវិនិច្ឆ័យរបស់គាត់ទៅលើការជំទាស់នោះ[50]។

---

ដាច់ដោយឡែកពីគ្នា គេបានសម្រេចថា "ខណៈដែលលក្ខន្តិកៈ និងវិធានផ្ទៃក្នុងមិនចែងច្បាស់លាស់អំពីការលាតត្រដាងនូវសម្ភារៈពីចៅក្រមមួយរូប ពាក់ព័ន្ធនឹងសំណើសុំប្តឹងជំទាស់ គេក៏មិនបានរារាំងភាគីមួយមិនឲ្យស្នើសុំការលាតត្រដាងនូវព័ត៌មានពាក់ព័ន្ធនឹងបញ្ហានេះដែរ។... គួរចងចាំថា [ការសន្មតជាមុននៃភាពមិនលម្អៀង] សំណើសុំលាតត្រដាងត្រូវកំណត់ឲ្យជាក់លាក់អំពីសម្ភារៈ ឬព័ត៌មាន ដែលជាកម្មសិទ្ធិរបស់ចៅក្រម និងបង្កើតនូវភស្តុតាងបឋមមួយ បង្ហាញថា វានឹងឆ្លុះបង្ហាញអំពីភាពលម្អៀងជាក់ស្តែង ឬ ការកើតមាននូវភាពលម្អៀង"។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Karemera*, ICTR-98-44-AR73.15 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Joseph Nzirorera ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ III បដិសេធការលាតត្រដាងសំណៅមួយច្បាប់នៃការវាយតម្លៃជាលាយលក្ខណ៍អក្សររបស់ចៅក្រមប្រធានអំពីសមាជិកម្នាក់នៃក្រុមរដ្ឋអាជ្ញា ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០០៩ កថាខណ្ឌ១១។

[50] សូមមើលផងដែរ កថាខណ្ឌ៧៤នៃគោលការណ៍សីលធម៌ចៅក្រមរបស់ប្រទេសនូវែលសេឡែន សំដៅទៅលើដូចខាងក្រោម "យុត្តិសាស្ត្រច្បាប់មកពីប្រទេសនូវែលសេឡែន និងអូស្ត្រាលី" ថា "មានគុណតម្លៃក្នុងការដឹកនាំចៅក្រម"៖ *រឿងក្តី Aussie Airlines* ***តទល់នឹង*** *Australian Airlines Pty Ltd* (ឆ្នាំ១៩៩៦) 135 ALR 753, កថាខណ្ឌ៣៤-៤៤៖ "៣៤. វាជាអ្វី ដែល គេចង់បាន នៅគ្រាដំបូងបង្អស់ ក្នុងការចែង និងបែងចែករវាង កាលៈទេសៈដែលអាចបណ្តាលឲ្យកើតមាននូវកាតព្វកិច្ចនៃការលាតត្រដាង និងកាលៈទេសៈដែលបណ្តាលឲ្យកើតមាននូវកាតព្វកិច្ចក្នុងការប្តឹងជំទាស់។ ៣៥. ហេតុផលមួយចំនួនអាចត្រូវបានកំណត់សម្រាប់អត្ថិភាពនៃកាតព្វកិច្ចក្នុងការលាតត្រដាង។ ៣៦. ទីមួយ វាអាចត្រូវបានគេរំពឹងទុកថា ភាគីនឹងដឹង ទុកមួយឡែកសិនការដែលដឹកសួរ អំពីកាលៈទេសៈប្តឹងជំទាស់ជាសក្តានុពល ពាក់ព័ន្ធនឹងចៅក្រមមួយរូប ឬតុលាការមួយ.. ៣៩. ក្នុងដំណើរធម្មតា ភាគីគឺពឹងផ្អែកទាំងស្រុងទៅលើការលាតត្រដាង ក្នុងគោលបំណងពិចារណាថាតើបញ្ហាមួយនៃបណ្តឹងជំទាស់អាចកើតឡើង ឬអត់ ហើយប្រសិនបើដូច្នេះមែន ថាតើការអនុវត្តប្តឹងជំទាស់នឹងត្រូវធ្វើឬយ៉ាងណា។ ៤០. ទីពីរ ការខកខានមិនលាតត្រដាង ដោយខ្លួនវាផ្ទាល់ អាចជាមួយនៃកាលៈទេសៈនានា ដែលអមជាមួយនឹងអ្វីផ្សេងៗទៀត អាចបណ្តាលឲ្យកើតមានការស្វែងយល់ប្រកបដោយសុភវិនិច្ឆ័យនូវភាពលម្អៀង។ ភាគីមួយ ឬសាធារណជនអាចមានចំណាប់អារម្មណ៍ថា មានការបិទបាំង ឬការមិនលាតត្រដាងដោយចេតនា ឬថា អ្វីម្យ៉ាង "ខុសឆ្គង" ហើយ។ ការខកខានមិនលាតត្រដាង បើទោះជាដោយមិនដឹងខ្លួនយ៉ាងណាក៏ដោយ អាចធ្វើឲ្យអន្តរាយដល់ទំនុកចិត្តរបស់សាធារណជនទៅលើសុចរិតភាព និងរដ្ឋបាលនៃយុត្តិធម៌ដោយមន្ត្រីតុលាការ ឬតុលាការពាក់ព័ន្ធ។ ៤១. ទីបី ការលាតត្រដាងខ្លួនវាផ្ទាល់ ជួយយ៉ាងសំខាន់ក្នុងការធានាសុវត្ថិភាព វត្ថុដែល

34. ដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចនៃវិរិយភាពទាន់ពេលវេលារបស់ខ្លួន មេធាវីការពារក្តីមិនអាចនៅស្ងៀមបានទេ នៅពេលទទួលបានព័ត៌មានអំពីការប្រព្រឹត្តិនេះដែលចង្អុលបង្ហាញអំពីការជួបប្រជុំគ្នា មួយដែលអាចប៉ះពាល់ដល់ភាពមិនលម្អៀងរបស់ចៅក្រម Cartwright ឬបណ្តាលឲ្យកើតមានជាសត្យានុម័តនូវការលេចចេញនៃភាពលម្អៀង[51] ។

---

យុត្តិធម៌ត្រូវបានគេ "មើលឃើញ" ថាត្រូវបានអនុវត្តនោះ។ វាគឺពិតប្រាកដជាក់ស្តែងមែន ដែលភារកិច្ចក្នុងការលាតត្រដាងអាចកើតមានឡើង ពាក់ព័ន្ធនឹងកាលៈទេសៈ ដែលតុលាការស្គាល់ និងអាចមានចំនួនខ្លះ ប៉ុន្តែមិនទាំងអស់ទេ របស់ភាគី ឬអ្នកតំណាងផ្នែកច្បាប់របស់ពួកគេ។ ក្នុងកាលៈទេសៈបែបនោះ កាតព្វកិច្ចក្នុងការលាតត្រដាងអាចជាកាតព្វកិច្ចមួយ ដែលគ្រប់គ្រងដោយទាំងតុលាការផង និងដោយភាគីដែលដឹងឮកាលទេសៈពាក់ព័ន្ធនោះផង។ ៤២. ភារកិច្ចត្រូវបាននិយាយថា កើតឡើង ពាក់ព័ន្ធនឹងអង្គហេតុ ឬកាលៈទេសៈ ដែលអាច ឬមានសក្តានុពលប្តឹងជិតចិត្ត ខ. ការលាតត្រដាងនូវ "ការដោះស្រាយណាមួយ ដែលអាចបង្កើតនូវចំណាប់អារម្មណ៍លើភាពលម្អៀងដែលអាចកើតមាន"។ Gallop J បានពណ៌នាភារកិច្ច ថាជាអ្វីមួយសម្រាប់ចៅក្រម "ក្នុងការលាតត្រដាងអង្គហេតុមួយ ប្រសិនបើ ចំពោះគាត់ វាហាក់ដូចជា វាអាចត្រូវបានពិចារណាថាមានអានុភាពទៅលើអព្យាក្រិតភាពរបស់រូបគាត់"។ ៤៣. វាសំខាន់ ដែលត្រូវគូសបញ្ជាក់ថា បើទោះជាភារកិច្ចអាចត្រូវបានបង្កើតឡើងក្តី អង្គហេតុដែលត្រូវលាតត្រដាងគឺជាអង្គហេតុដែលអាចបង្កើត ឬធានានូវការអនុវត្តដោយសុទ្ធចិត្តចំពោះបណ្តឹងជិតចិត្ត។ វានឹងធ្វើឱ្យបរាជ័យនូវគោលបំណងនៃការលាតត្រដាង ប្រសិនបើវាគ្រាន់តែពាក់ព័ន្ធ ឬត្រូវបានគេមើលថាពាក់ព័ន្ធនឹងអង្គហេតុដែលធានាដល់បណ្តឹងជិតចិត្ត។ ៤៤. ប្រសិនជាអង្គហេតុដែលត្រូវបានលាតត្រដាងធានានូវបណ្តឹងជិតចិត្តជាបញ្ហាកើតឡើងបន្ទាប់ពីភារកិច្ចលាតត្រដាងត្រូវបានអនុវត្តត្រឹមត្រូវ។ ដូចគ្នាដែរ អង្គហេតុនៃការលាតត្រដាង ផ្ទុយប្រឆាំងនឹងការមិនលាត ប្រដាង មិនអាចបង្កើតឲ្យមានកាលៈទេសៈមួយ ដែលលម្អៀងទៅបណ្តឹងជិតចិត្តឡើយ"។ *ប៉ុន្តែ សូមមើល រឿងក្តី Clenae Pty Ltd តទល់នឹង ANZ Banking Group Ltd*, HCA M2/2000 ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០០ "ការខកខានមិនលាតត្រដាងគឺពាក់ព័ន្ធ (ប្រសិនបើមាន) ដោយព្រោះតែវាអាចជួយបំភ្លឺដល់សំណួរដើម្បីស្វែងយល់ប្រកបដោយសុភវិនិច្ឆ័យនូវភាពលម្អៀង។ ការខកខានមិនបានលាតត្រដាងពុំមានសារៈសំខាន់ផ្នែកច្បាប់ផ្សេងទៀតឡើយ"។

[51] សារៈសំខាន់នៃករណីកិច្ចធ្វើសកម្មដោយវិរិយភាពដោយធ្វើបណ្តឹងជិតចិត្តចៅក្រម ត្រូវបានពន្យល់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅ ICTY នៅក្នុងរឿងក្តី *Čelebić* "ការខកខានរបស់មេធាវីក្នុងការជំទាស់ ឬការអំពាវនាវសុំការយកចិត្តទុកដាក់ ចំពោះការសម្រាន្ត ឬការមិនយកចិត្តទុកដាក់របស់ចៅក្រម ក្នុងអំឡុងពេលនៃដំណើរការនីតិវិធី គឺពាក់ព័ន្ធនឹងសំណួរថាតើកើតមានភាពលម្អៀង ឬអត់។ ការខកខានរបស់មេធាវីក្នុងការជំទាស់នឹងបង្ហាញថា មេធាវីនោះមាន ទស្សនៈក្នុងគ្រាពេលនោះថា បញ្ហាផ្សេងៗដែលចៅក្រមរូបនោះមិនយកចិត្តទុកដាក់ គឺពុំមានសារៈសំខាន់អ្វីឡើយក្នុងរឿងក្តីរបស់ខ្លួន ដែលដំណើរការនីតិវិធីមិនអាចបន្តទៅទៀតបាន ដោយពុំមានការអំពាវនាវសុំការយកចិត្តទុកដាក់លើបញ្ហានោះទេ ។*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Delalić *និងអ្នកផ្សេងទៀត* IT-96-21-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ៦៣១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera*, ICTR-98-44-AR15*bis*.2, ហេតុផល ចំពោះសេចក្តីសម្រេចលើបណ្តឹងចាត់របៀប ពាក់ព័ន្ធនឹងការបន្តដំណើរការនីតិវិធីជាមួយនឹងចៅក្រមជំនួស និងស្តីពីញត្តិរបស់ Nzirorera ស្នើសុំឱ្យពិចារណាសម្ភារៈថ្មីៗ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Sesay និង អ្នកផ្សេងទៀត* SCSL-2004-AR15-15 សេចក្តីសម្រេចស្តីពីញត្តិរបស់មេធាវីការពារក្តីសុំឱ្យចៅក្រម Robertson ដកខ្លួនចេញពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍

### *គ. ការប្រាស្រ័យទាក់ទងជាមួយតែភាគីម្ខាង រវាងចៅក្រម* Cartwright និង លោក Cayley អាចបណ្តាលឲ្យកើតមាននូវការរំលោភលើវិធាននានានៃក្រមវិជ្ជាជីវៈ ដែលលោក Cayley មានកាតព្វកិច្ចអនុវត្ត

35. ខណៈដែលមេធាវីការពារក្តីគួសបញ្ជាក់ជាមួយលោក Cayley ថាខ្លួនក្នុងពេលណាមួយ ខ្លួនហាក់ពុំមានសេចក្តីថ្លៃថ្នូរ ក្នុងការតម្រូវឲ្យឆ្លើយសំណួរ នៅពេលដែលសុច្ចរិតភាពរបស់បុគ្គលម្នាក់មានបញ្ហានោះ ខ្លួនមិនអាចអាណិតអាសូរដល់លោក Cayley នៅពេលមានការអះអាងថា ទំនាក់ទំនង*សម្ងាត់*កើតមានឡើង ថ្វីបើមានការតវ៉ារបស់រូបគាត់ក្តី។ ក្នុងនាមជាមេធាវីនៃប្រទេសអង់គ្លេស និងវេល លោក Cayley គួរ ឬបានដឹងថា ទំនាក់ទំនងសម្ងាត់រវាងរាជអាជ្ញា និងចៅក្រមអាចប៉ះពាល់ដល់រដ្ឋបាលនៃយុត្តិធម៌ និងអាចកាត់បន្ថយទំនុកចិត្តរបស់សាធារណៈចំពោះវិជ្ជាជីវៈផ្នែកច្បាប់ ឬបណ្តាលឲ្យមានឈ្មោះអាក្រក់ដល់វិជ្ជាជីវៈ។ ក្រមសីលធម៌ចៅក្រមកម្ពុជាអាចយកមកអនុវត្តបានចំពោះលោក Cayley,[52] រួមទាំងមាត្រា៩ (ហាមប្រាមទំនាក់ទំនងសម្ងាត់រវាងចៅក្រម និងភាគីម្ខាង)។ លោក Cayley ក៏គួរដឹងដែរថា មេធាវីដែលជាគូជំទាស់ ដោយមានតារាងអង្គហេតុនេះ គ្មានជម្រើសណាក្រៅពីការស្វែងរកការពិតនោះឡើយ។ ដើម្បីបកស្រាយលោក Cayley៖ ច្បាប់ចងភ្ជាប់កាតព្វកិច្ចឲ្យមេធាវីការពារក្តីធ្វើបែបនេះ[53]។ ប្រាកដណាស់ នេះក៏ដោយសារមាន "វិបត្តិនៃភាពគួរឲ្យជឿជាក់" កំពុងរាតត្បាតអ.វ.ត.ក[54]។

---

ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤។ នៅក្នុងរឿងក្តីទាំងនេះ ប្រសិនបើមេធាវីការពារក្តីពុំបានបំពេញ មុខនាទីដោយវីរិយភាពទាន់ពេលវេលាទេនោះ ចៅក្រមដែលជាប់ពាក់ព័ន្ធដែលចុងក្រោយ ត្រូវបានរកឃើញថា ពុំមានសម្បទាជំនុំជម្រះលើសំណុំរឿងដោយសារតែភាពលម្អៀង ឬការបង្ហាញនូវភាពលម្អៀងនឹងនៅតែជំនុំជម្រះក្នុងរឿងក្តីដដែល ដែលបណ្តាលឲ្យមានអន្តរាយដល់សិទ្ធិរបស់កូនក្តីរបស់ពួកគេក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[52] ក្រមសីលធម៌កម្ពុជាគឺអនុវត្តចំពោះអ្នកដែលកាន់មុខតំណែងចៅក្រម និងព្រះរាជអាជ្ញា។ មាត្រាមួយនៃក្រមសីលធម៌នេះចែងថា "ក្នុងក្រមសីលធម៌នេះ "ចៅក្រម" សំដៅទៅលើ ចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញា"។

[53] *សូមមើល* Andrew Cayley *សម្រង់ពាក្យសំដី*នៅសំឡេងសហរដ្ឋអាមេរិក *ព្រះរាជអាជ្ញាយូអិនៈ "ច្បាប់ភ្ជាប់កាតព្វកិច្ចឲ្យខ្ញុំធ្វើបែបនេះ"* ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ *ដែលអាចរកមើលបាននៅ* http://www.voanews.com/khmer-english/news/UN-Prosecutor-The-Law-Ties-Me-To-Do-This-133245133.html: "ខ្ញុំត្រូវតែអនុវត្តតាមវិធានច្បាប់។ ខ្ញុំមិនអាចទទួលការណែនាំពីរដ្ឋាភិបាលបានទេ។ រដ្ឋាភិបាលមិនអាចនិយាយប្រាប់ខ្ញុំ ហើយតាមពិត ពួកគេមិនដែលទាំងនិយាយមកខ្ញុំដោយផ្ទាល់ឡើយ "សុំទោសអ្នកមិនអាចដាក់ឯកសារនោះនៅតុលាការបានទេ"។ វាត្រូវតែនាំទៅដល់ទីបញ្ចប់ផ្នែកច្បាប់។ វាត្រូវតែអនុវត្តទៅតាមដំណើរការត្រឹមត្រូវ។ យើងត្រូវតែអនុវត្តទៅតាមវិធានច្បាប់។ យើងត្រូវតែអនុវត្តទៅតាមច្បាប់ ហើយ

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចដែលបានលើកឡើងខាងលើ និងដោយក្តីគោរព មេធាវីការពារក្តីសូមស្នើដោយក្តីគោរពឲ្យចៅក្រម Silvia Cartwright ដកខ្លួនចេញពីរាល់ដំណើរការនីតិវិធីរហូតទាល់តែសំណើនេះត្រូវបានសម្រេច និងដល់អង្គជំនុំជម្រះសាលាដំបូងសូមមេត្តា៖

ក. ស៊ើបអង្កេតថាតើបញ្ហាពាក់ព័ន្ធនឹងសំណុំរឿង០០២ត្រូវបានពិភាក្សា ក្នុងអំឡុងការជួបប្រជុំណាមួយរវាង ឬក្នុងចំណោមចៅក្រម Cartwright និងលោក Cayley ឬអត់ បើទោះជាក្នុងវត្តមានបុគ្គលណាផ្សេងទៀត ឬគ្មានក៏ដោយនោះ

ខ. កោះហៅបុគ្គលដែលស្នើសុំ និងបង្គាប់ឲ្យពួកគេលាតត្រដាងនូវព័ត៌មានតាមការស្នើសុំ

គ. លើកទឹកចិត្តឲ្យចៅក្រម Silvia Cartwright ធ្វើសេចក្តីថ្លែងការណ៍មួយលាតត្រដាងអំពីព័ត៌មានតាមការស្នើសុំ និង

ឃ. បើកសវនាការសាធារណៈផ្ទាល់មាត់មួយ ដើម្បីសម្រេចលើសំណើនេះ ឬជម្រើសផ្សេងពីនេះអនុញ្ញាតឲ្យឆ្លើយតបទៅនឹងរាល់សារណាដែលដាក់ជាចម្លើយតបទៅនឹងសំណើនេះ។

សូមលោក-លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម                    Michael G. KARNAVAS

សហមេធាវីការពារក្តីរបស់ លោក អៀង សារី

*ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១*

---

យើងត្រូវទៅដល់សេចក្តីសន្និដ្ឋានផ្នែកតុលាការក្នុងករណីនោះ។ នោះឯងជាច្បាប់។ នោះឯងជាកាតព្វកិច្ចរបស់ខ្ញុំ។ នោះឯងជាភារកិច្ចរបស់ខ្ញុំ គឺត្រូវអនុវត្តតាមច្បាប់។ ខ្ញុំមិនអាចធ្វើអ្វីទៀតបានឡើយ។ ច្បាប់ភ្ជាប់កាតព្វកិច្ចឲ្យខ្ញុំធ្វើបែបនេះ”។

[54] *សូមមើល* អង្គការ Open Society Justice Initiative (“OSJI”) ការវិវឌ្ឍថ្មីៗនៅអ.វ.ត.ក ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ២០ *អាចមើលបាននៅ* http://www.soros.org/initiatives/justice/articles_publications/publications/cambodia-court-20111114.